ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

# របាយការណ៍
# ស្តីពី
# សភាពការណ៍កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
# ប្រចាំឆ្នាំ២០១៣

## I- សភាពការណ៍រួម

ការប្រែប្រួលអាកាសធាតុគឺជាកត្តាដែលនាំឲ្យមានការលំបាកក្នុងការបង្កបង្កើនផលស្រូវ ជាក់ស្តែងនៅក្នុងឆ្នាំ២០១៣នេះស្ថានភាពទឹកភ្លៀងបានចាប់ផ្តើមធ្លាក់ពីដើមរដូវវស្សា។ ក្នុងឆ្នាំនេះកសិករបានជួបប្រទះនូវគ្រោះធម្មជាតិ(កង្វះខាតទឹក និងទឹកជំនន់)ដែលជះឥទ្ធិពលអវិជ្ជមានដល់ការងារបង្កបង្កើនផល។ បញ្ហាកង្វះខាតទឹកនៅកណ្តាលរដូវវស្សាបានកើតមានចាប់ពីចុងខែសីហារហូតដល់សប្តាហ៍ទី២នៃខែកញ្ញា ដែលបណ្តាលឲ្យប៉ះពាល់ដល់ការងារផលិតកម្មកសិកម្មក្នុងខេត្តចំនួន០៥ ដូចជា៖ ខេត្តកំពង់ស្ពឺ កំពត កណ្តាល ស្វាយរៀង និងខេត្តតាកែវ។ ដោយឡែក ទឹកជំនន់ចំនួន០២លើក ក្នុងនោះជំនន់ទឹកភ្លៀងលើកទី១បានកើតមានឡើងចាប់ពីសប្តាហ៍ទី៣នៃខែសីហា រហូតដល់ដើមសប្តាហ៍ទី១នៃខែកញ្ញា ហើយនិងជំនន់ទឹកភ្លៀងលើកទី២ ព្រមជាមួយនឹងជំនន់ទឹកទន្លេមេគង្គបានចាប់មានពីសប្តាហ៍ទី៤ នៃខែកញ្ញា រហូតមកដល់សប្តាហ៍ទី២នៃខែតុលា ដែលបានប៉ះពាល់និងបណ្តាលឲ្យខូចខាតដល់ដំណាំកសិកម្មនៅបណ្តារាជធានីខេត្តចំនួន២១ ដូចជា៖ ខេត្តបន្ទាយមានជ័យ បាត់ដំបង កំពង់ចាម កំពង់ឆ្នាំង កំពង់ធំ កណ្តាល កោះកុង ក្រចេះ មណ្ឌលគិរី រាជធានីភ្នំពេញ ព្រះវិហារ ព្រៃវែង ពោធិ៍សាត់ រតនគិរី សៀមរាប ព្រះសីហនុ ស្ទឹងត្រែង ស្វាយរៀង តាកែវ ឧត្តរមានជ័យ និងខេត្តប៉ៃលិន។ ជារួមស្ថានភាពនៃអាកាសធាតុបែបនេះបានបណ្តាលឲ្យប៉ះពាល់ដល់ទំហំផ្ទៃដីបង្កបង្កើនផល ការលូតលាស់របស់ដំណាំស្រូវនិងបង្កការខូចខាតដល់ដំណាំរដូវវស្សាមួយចំនួន។ តែទោះជាយ៉ាងណាលទ្ធផលនៃការងារបង្កបង្កើនផលក៏ដូចជាសកម្មភាពតាមផ្នែកនីមួយៗទទួលបានជាវិជ្ជមានតាមការរំពឹងទុកស្របតាមទិសដៅដែលបានដាក់ចុះ។

## II- លទ្ធផលសម្រេចបានតាមបណ្តាផ្នែក

### ១ ផ្នែកដាំដុះ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានប្រជុំបូកសរុបបឋមលើការងារបង្កបង្កើនផលរដូវវស្សាឆ្នាំ២០១៣ ការប៉ាន់ស្មានអំពីការងារបង្កបង្កើនផលរដូវប្រាំងឆ្នាំ២០១៣-២០១៤ និងការព្យាករណ៍គុណភាពស្បៀងជំហានដំបូងសម្រាប់ឆ្នាំ២០១៤។ លទ្ធផលនៃការវាយតម្លៃបឋមនេះមានលម្អិតដូចខាងក្រោម៖

#### ១.១ ដំណាំស្រូវរដូវវស្សាឆ្នាំ២០១៣

-ផ្ទៃដីភ្ជួររាស់សរុបចំនួន៣.២៧៤.៧៥៨ហិកតា លើសឆ្នាំមុនចំនួន១១៦.៣៤៨ហិកតា (ក្នុងនោះភ្ជួររាស់ដោយគោ-ក្របីចំនួន៩៦០.៦៨៩ហិកតា តិចជាងឆ្នាំមុន ២១៣.៣០៤ហិកតា )

-ផ្ទៃដីសាបសរុបចំនួន១៥៨.៨៩០ហិកតា តិចជាងឆ្នាំមុនចំនួន១៧.០៩៥ហិកតា

-ផ្ទៃដីសន្ទូង ពង្រោះ និងបុកដាំសរុបចំនួន២.៥៦៧.៧៦២ហិកតា ស្មើនឹង១០៧,០១ភាគរយ នៃផែនការ ២.៣៩៩.៦៣៧ហិកតា លើសឆ្នាំមុនចំនួន៥៦.០៦៨ហិកតា រួមមាន៖

- ស្រូវស្រាលចំនួន៦៦០.២៩៩ហិកតា តិចជាងឆ្នាំមុនចំនួន១៨.១៥៤ហិកតា (ក្នុងនោះស្រូវបង្កើនរដូវចំនួន១៨៩.៣៦៣ហិកតា តិចជាងឆ្នាំមុន៥៩.៦០១ហិកតា)
- ស្រូវកណ្តាលចំនួន១.២៣៥.៩៧០ហិកតា លើសឆ្នាំមុន៥១.៣៨៤ហិកតា



អាស័យដ្ឋានលេខ ២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា
Nº 200 Preah Norodom Sangkat Tonle Basak Khan Chamkarmon B V D Phnom Penh, Cambodia
ទូរស័ព្ទលេខ : (០២៣) ២១១ ៣៥១ / ២១១ ៣៥២ ទូរសារលេខ : (៨៥៥) ២៣-២១៧ ៣២០
Phone : (023) 211 351/211 352, Fax : (855) 23 - 217 320

• ស្រូវធ្ងន់ចំនួន៥៥៧.៨៦៩ហិកតា លើសឆ្នាំមុន២៨.៦០៨ហិកតា
• ស្រូវចម្ការចំនួន៤៧.៥៥២ហិកតា តិចជាងឆ្នាំមុន៣.០២៦ហិកតា
• ស្រូវឡើងទឹកចំនួន៦៦.០៧២ហិកតា តិចជាងឆ្នាំមុន២.៧៤៤ហិកតា។

-ផ្ទៃដីប៉ះពាល់និងខូចខាតដោយគ្រោះធម្មជាតិ ៖

• សំណាបប៉ះពាល់សរុបចំនួន៧៥១ហិកតា ក្នុងនោះខូចខាតចំនួន១២១ហិកតា
• សន្ទូង-ពង្រោះប៉ះពាល់សរុបចំនួន៣៨១.២៩១ហិកតា (ស្មើនឹង១៤,៨៥%នៃផ្ទៃដីអនុវត្ត) ក្នុងនោះខូចខាតចំនួន១២៨.៤០០ហិកតា(ក្នុងនោះ៥%នៃផ្ទៃដីអនុវត្ត) ដោយ៖

+រាំងស្ងួត៖

-សំណាបប៉ះពាល់ចំនួន៦៣១ហិកតា ក្នុងនោះខូចខាតចំនួន៣៩ហិកតា

-សន្ទូង-ពង្រោះប៉ះពាល់ចំនួន៨.៣៦៣ហិកតា។

+ទឹកជំនន់៖

-សំណាបប៉ះពាល់ចំនួន១២០ហិកតា ក្នុងនោះខូចខាតចំនួន៨២ហិកតា

-សន្ទូង-ពង្រោះប៉ះពាល់ចំនួន៣៧២.៩២៨ហិកតាក្នុងនោះខូចខាតចំនួន១២៨.៤០០ហិកតា។

-លទ្ធផលនៃការស្តារផ្ទៃដីខូចខាតឡើងវិញ៖

• ផ្ទៃដីស្តារបានឡើងវិញចំនួន៤៦.១៩៧ហិកតា (ស្មើនឹង៣៥,៩៨%នៃផ្ទៃដីខូចខាតសរុប)។

-ផ្ទៃដីអាចប្រមូលផល៖

• ការងារប្រមូលផលស្រូវរដូវវស្សាសម្រេចបានលើផ្ទៃដីចំនួន២.៤៨៥.៥៥៩ហិកតា លើសរដូវវស្សាឆ្នាំ២០១២ ចំនួន៧២៧ហិកតា ក្នុងនោះទិន្នផលជាមធ្យមចំនួន២,៩២១តោនក្នុងមួយហិកតា លើសឆ្នាំមុនចំនួន៥៩គ.ក្រក្នុងមួយហិកតា និងបរិមាណផលសរុបចំនួន៧.២៥៩.៨៨៩តោន លើសឆ្នាំមុនចំនួន១២៣.៨៥០តោន។

## ១.២ លទ្ធផលប៉ាន់ស្មានដំណាំស្រូវរដូវប្រាំងឆ្នាំ២០១៣-២០១៤៖

ការងារបង្កបង្កើនផលស្រូវរដូវប្រាំងឆ្នាំ២០១៣-២០១៤ រហូតមកទល់ពេលនេះ មានល្បឿនយឺតជាងឆ្នាំមុនចំនួន១៩២.១៧០ហិកតា(ស្មើនឹង៥០,០៩%នៃផែនការ៣៨៣.៦៤០ហិកតា)។ ដោយផ្អែកលើនិន្នាការនេះ រួមជាមួយការវាយតម្លៃទៅលើស្ថានភាពលូតលាស់នៃដំណាំនិងការត្រៀមលក្ខណៈនានា លទ្ធផលប៉ាន់ស្មានដំណាំស្រូវរដូវប្រាំងឆ្នាំ២០១៣-២០១៤ នឹងអាចសម្រេចបានផ្ទៃដីដាំដុះសរុប៤៧២.៤៨៣ហិកតា ស្មើនឹង១២៣,១៦% នៃផែនការសរុប៣៨៣.៦៤០ហិកតា តិចជាងឆ្នាំមុនចំនួន២៣.១៦៥ហិកតា ក្នុងនោះផ្ទៃប្រមូលផលប៉ាន់ស្មានសរុបចំនួន៤៧២.២៣២ហិកតា ដែលនឹងមានបរិមាណផលសរុបចំនួន២.០៨០.៤០១តោន ក្នុងកម្រិតទិន្នផលប៉ាន់ស្មានជាមធ្យម៤,៤០៥តោនក្នុងមួយហិកតា (ទិន្នផលឆ្នាំមុន៤,៣៤៩តោនក្នុងមួយហិកតា)។

## ១.៣ លទ្ធផលប៉ាន់ស្មានតុល្យភាពស្បៀងសម្រាប់ឆ្នាំ២០១៣-២០១៤៖

| កម្រិតកំណត់ | ឯកតា | រដូវវស្សា | រដូវប្រាំង | សរុប |
|---|---|---|---|---|
| - ផែនការដាំដុះ | ហត | ២.៣៩៩.៦៣៧ | ៣៨៣.៦៤០ | ២.៧៨៣.២៧៧ |
| - ផ្ទៃដីអនុវត្ត | ហត | ២.៥៦៧.៧៦២ | ៤៧២.៤៨៣ | ៣.០៤០.២៤៥ |
| - ផ្ទៃដីខូចខាត | ហត | ១២៨.៤០០ | ៥៨១ | ១២៨.៩៨១ |
| - ផ្ទៃដីស្តារបាន | ហត | ៤៦.១៩៧ | ០ | ៤៦.១៩៧ |
| - ផ្ទៃដីប្រមូលផល | ហត | ២.៤៨៥.៥៥៩ | ៤៧២.២៣២ | ២.៩៥៧.៧៩១ |
| - ទិន្នផលមធ្យម | ត/ហត | ២,៩២១ | ៤,៤០៥ | ៣,១៥៨ |
| - បរិមាណផលសរុប | តោន | ៧.២៥៩.៨៨៩ | ២.០៨០.៤០១ | ៩.៣៤០.៣៩០ |

ដូច្នេះ តុល្យភាពស្បៀងសម្រាប់ឆ្នាំ២០១៣ មានដូចខាងក្រោមនេះ៖

• កាត់ចេញ១៣%សម្រាប់ទុកពូជ ចំណីសត្វ និងបាត់បង់ដោយការប្រមូលផល ១.២១៤.២៥១តោន
• ស្រូវនៅសល់ជាស្បៀង ៨.១២៦.១៤០តោន

• សរុបបរិមាណស្រូវគិតជាអង្ករ៦៤%                                    ៥.២០០.៧២៩តោន
• តម្រូវការអង្ករជាស្បៀងសម្រាប់ប្រជាជនចំនួន១៤.៩៥០.១៩៦(នាក់)         ២.១៣៧.៨៧៨តោន
• អតិរេកអង្ករ សម្រាប់បម្រើឱ្យគោលដៅនាំចេញ                           ៣.០៦២.៨៥១តោន
• អតិរេកស្រូវ                                                      ៤.៧៨៥.៧០៥តោន

គួរកត់សម្គាល់ថា រាជរដ្ឋាភិបាលកម្ពុជាបានកំណត់យកឆ្នាំ២០១៥ជាឆ្នាំគោល ដើម្បីជំរុញការផលិតស្រូវឱ្យបានច្រើនជាង៤លានតោន និងគិតជាបរិមាណអង្ករសម្រាប់នាំចេញជាផ្លូវការត្រូវសម្រេចឱ្យបានយ៉ាងតិច១លានតោន។ បើពិនិត្យលើអតិរេកស្រូវសម្រេចបាននៅឆ្នាំ២០១៣នេះមានរហូតដល់ជាង៤,៧៨ លានតោន គឺលើសផែនការកំណត់។ នេះជាជោគជ័យមួយគួរជាទីមោទនៈបំផុតសម្រាប់កម្ពុជា ក្នុងការជំរុញផលិតកម្មដំណាំស្រូវ។ ដោយឡែកក្នុងរយៈពេល ១២ខែឆ្នាំនេះ បរិមាណនាំចេញអង្ករបានកើនដល់ចំនួន៣៧៨.៨៥៦តោន ដែលក្នុងរយៈពេល១២ខែឆ្នាំ២០១២ មានតែ២០៥.៧១៧តោនប៉ុណ្ណោះ(មានកំណើន១៧៣.១៣៩តោន ឬ៨៤,១%) ដោយបាននាំចេញទៅកាន់ទិសដៅចំនួន៦៦ ប្រទេស។

## ១.៤ លទ្ធផលប៉ាន់ស្មានដំណាំរួមផ្សំនិងដំណាំឧស្សាហកម្មឆ្នាំ២០១៣-២០១៤

### ១.៤.១ លទ្ធផលសម្រេចបានរដូវវស្សាឆ្នាំ២០១៣

ក- ដំណាំរួមផ្សំ

ផ្ទៃដីសម្រេចបានចំនួន៦៧៧.៨១៤ហិកតាស្មើនឹង១៣១,០៤ភាគរយ នៃផែនការសរុប៥១៧.២៦០ហិកតា លើសឆ្នាំមុន៧១.៦៣១ហិកតា និងបរិមាណផលសរុបចំនួន៨.៦៣៣.៥៨៤តោន លើសឆ្នាំមុន៦៩៨.០៨៨តោន។

ខ- ដំណាំឧស្សាហកម្ម

ផ្ទៃដីសម្រេចបាន១៤៨.១៩៣ហិកតា ស្មើនឹង៩៥,៩៦ភាគរយ នៃផែនការសរុប១៥៤.៤២៩ហិកតា តិចជាងឆ្នាំមុន១៥.៤១៥ហិកតា និងបរិមាណផលសរុបចំនួន៨៨២.០០៣តោន តិចជាងឆ្នាំមុន៧០៧.៥៨៤តោន។

### ១.៤.២ ការប៉ាន់ស្មានដំណាំរដូវប្រាំងឆ្នាំ២០១២-២០១៣

ក- ដំណាំរួមផ្សំ

ផ្ទៃដីសម្រេចបានចំនួន៥៩.៦៧៨ហិកតាស្មើនឹង១៣៥,៨០ភាគរយ នៃផែនការសរុប៤៣.៩៤៤ហិកតា តិចជាងឆ្នាំមុន១៦.០៩៦ហិកតា និងបរិមាណផលសរុបចំនួន៣៤៦.៦០៧តោន តិចជាងឆ្នាំមុន៨១៧.៣៦៩តោន។

ខ- ដំណាំឧស្សាហកម្ម

ផ្ទៃដីសម្រេចបាន១៣.៩៧៥ហិកតា ស្មើនឹង៦៧,៧៣ភាគរយ នៃផែនការសរុប២០.០៨៤ហិកតា តិចជាងឆ្នាំមុន៣.៧៤៣ហិកតា និងបរិមាណផលសរុបចំនួន១៦៨.៦៧៩តោន តិចជាងឆ្នាំមុន២.០៦៩តោន។

## ១.៥ ស្ថិតិគ្រឿងយន្តនិងឧបករណ៍ផលិតកម្មកសិកម្ម

-ត្រាក់ទ័រចំនួន៦.២៣២គ្រឿង គោយន្តចំនួន១០៣.០០៩គ្រឿង ម៉ាស៊ីនបូមទឹកចំនួន២៣៩.៦៧៦គ្រឿង ម៉ាស៊ីនច្រូតចំនួន៤.០៤៨គ្រឿង ម៉ាស៊ីនបោក-បុកស្រូវចំនួន១១.៨០៩គ្រឿង ម៉ាស៊ីនសម្ងួតចំនួន៥៦គ្រឿង និងម៉ាស៊ីនកិនស្រូវចំនួន៤១.៦០៥គ្រឿង។

# ២ ផ្នែកកៅស៊ូ

សក្តានុពលនៃការអភិវឌ្ឍកៅស៊ូមានសន្ទុះរីកចម្រើនខ្លាំងពីមួយឆ្នាំទៅមួយឆ្នាំ ជាមួយនឹងសកម្មភាពនៃការដាំដុះស្ទើរគ្រប់តំបន់នៅក្នុងទូទាំងប្រទេស។ សកម្មភាពនេះបានបង្ហាញឱ្យឃើញអំពីស្ថានភាពអំណោយផលនៃផ្នែកភូមិសាស្ត្រ បរិស្ថាន និងភាពអនុគ្រោះដ៏ប្រសើររួមមានផ្នែកសន្តិសុខ សុវត្ថិភាព បណ្តាញគមនាគមន៍ ព័ត៌មាន កម្លាំងពលកម្ម ការចូលរួមរបស់អាជ្ញាធរគ្រប់លំដាប់ថ្នាក់និងប្រជាពលរដ្ឋ គួបផ្សំនឹងគោលនយោបាយសេរីភាវូបនីយកម្មផ្នែកសេដ្ឋកិច្ចពាណិជ្ជកម្មសំដៅជំរុញនិងលើកទឹកចិត្តដល់ការវិនិយោគសមស្របតាមយុទ្ធសាស្ត្រចតុកោណដំណាក់ទី៣ និងជាពិសេសគោលនយោបាយលើកទឹកចិត្តដល់កសិករ ក្នុងការចូលរួមដាំដុះកៅស៊ូនៅលើដីចម្ការរបស់ខ្លួន។ អគ្គនាយកដ្ឋានកៅស៊ូនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មានបេសកកម្មជានាការអភិវឌ្ឍនិងការគ្រប់គ្រងវិស័យកៅស៊ូគ្រប់ផ្នែក ដើម្បីរួមចំណែកជំរុញកំណើនសេដ្ឋកិច្ចជាតិ សេដ្ឋកិច្ចគ្រួសារ និងសង្គមសំដៅកាត់បន្ថយភាពក្រីក្រ លើកកម្ពស់គុណភាពផលិតផលកៅស៊ូ ដើម្បីធានាដល់ការប្រកួតប្រជែងនៅលើទីផ្សារតាមរយៈការផ្តល់សេវាស្រាវជ្រាវ និងការផ្សព្វផ្សាយបច្ចេកវិទ្យាប្រកបដោយ

ប្រសិទ្ធភាពព្រមទាំងការអភិវឌ្ឍ និងការគ្រប់គ្រងខ្សែចង្វាក់ផលិតកម្ម អាជីវកម្មកែច្នៃសំដៅជំរុញពាណិជ្ជកម្មផលិតផលកៅស៊ូប្រកបដោយវឌ្ឍនភាព។

ត្រឹមឆ្នាំ២០១៣នេះ ផ្ទៃដីកៅស៊ូសរុបមានចំនួន៣២៥.៩០៥ហិកតា គឺកើនឡើងចំនួន១៦.៣៦% បើធៀបទៅនឹងឆ្នាំ២០១២ (២៨០.៣៥៥ហិកតា)។ ក្នុងនោះផ្ទៃដីចម្ការកៅស៊ូកសិឧស្សាហកម្មមានចំនួន៥៥.៨៩៥ហិកតា (ស្មើនឹង១៧,១៥%នៃផ្ទៃដីសរុប) ផ្ទៃដីចម្ការកៅស៊ូវិនិយោគលើដីសម្បទានសេដ្ឋកិច្ចមានចំនួន១៣៥.៤៤៦ហិកតា (ស្មើនឹង៤១,៥៦%) និងផ្ទៃដីចម្ការកៅស៊ូគ្រួសារមានចំនួន១៣៤.៥៦៣ហិកតា (ស្មើនឹង៤៦,២៩%)។ ផ្ទៃដីចៀរជ័រសរុបមានចំនួន៧៨.៤៤៤ហិកតា ដោយទទួលបានផលិតផលចំនួន៩០.០០០តោន។

**តារាងសរុបផ្ទៃដីដាំកៅស៊ូឆ្នាំ២០១៣**

| ចម្ការកៅស៊ូ | ផ្ទៃដី (ហត) | | | | ភាគរយ |
|---|---|---|---|---|---|
| | សម្បទាន | ចៀរជ័រ | ថែទាំ | សរុប | |
| ចម្ការកៅស៊ូកសិឧស្សាហកម្ម (Ex-Estates) | 73,906 | 25,938 | 29,957 | 55,895 | 17% |
| ចម្ការកៅស៊ូកសិឧស្សាហកម្ម (ELCs) | 539,574 | 0 | 135,446 | 135,446 | 42% |
| ចម្ការកៅស៊ូគ្រួសារ | 0 | 52,505 | 82,056 | 134,561 | 41% |
| **សរុប** | 613,481 | 78,443 | 247,459 | 325,902 | 100% |

នៅក្នុងឆ្នាំ២០១៣នេះកៅស៊ូគ្រួសារបានដាំនៅក្នុងខេត្តចំនួន១៨ រួមមាន: រតនគិរី ស្ទឹងត្រែង ក្រចេះ មណ្ឌលគិរី កំពង់ចាម កំពង់ធំ ព្រះវិហារ បាត់ដំបង ប៉ៃលិន ពោធិ៍សាត់ បន្ទាយមានជ័យ សៀមរាប ឧត្តរមានជ័យ កោះកុង ព្រះសីហនុ កំពត ព្រៃវែង និងស្វាយរៀងដែលមានផ្ទៃដីដាំដុះចំនួន១៣៤.៥៦១ហ.ត ស្មើនឹងចំនួន២៧.៦៩៧គ្រួសារ។ ចំពោះទិន្នន័យរោងចក្រសិប្បកម្មកែច្នៃផលិតផលកៅស៊ូនៅទូទាំងប្រទេស ជាសរុបមានរោងចក្រសិប្បកម្មកែច្នៃផលិតផលកៅស៊ូចំនួន៦០ ក្នុងនោះមានរោងចក្រកែច្នៃជ័រកៅស៊ូចំនួន២៣ សិប្បកម្មកែច្នៃជ័រកៅស៊ូសន្លឹកចំនួន៣៣ និងរោងចក្រកែច្នៃឈើកៅស៊ូចំនួន៤។ តាមការព្យាករណ៍រហូតដល់ឆ្នាំ២០១៨ ផ្ទៃដីកៅស៊ូកម្ពុជានឹងកើនឡើងដល់ប្រមាណ៤២០.០០០ហិកតា ហើយដល់ឆ្នាំ២០២០ ផ្ទៃដីកៅស៊ូនឹងកើនដល់ជាង៤៥០.០០០ហិកតា ដែលអាចនឹងផ្តល់ជ័រកៅស៊ូប្រមាណ៤០-៥០ម៉ឺនតោនក្នុងមួយឆ្នាំ។ ដោយឡែក ច្បាប់ស្តីពីកៅស៊ូក៏ដូចជាការអនុវត្តគម្រោងធម្មនិយាមកម្មច្បារពូជកៅស៊ូកំពុងប្រព្រឹត្តទៅយ៉ាងសកម្មក្រោមកិច្ចសហការជាមួយទីភ្នាក់ងារបារាំងសម្រាប់ការអភិវឌ្ឍនៅកម្ពុជា(AFD)។

## ៣ ផ្នែកផលិតកម្មនិងបសុព្យាបាល

ការងារផលិតកម្មសត្វនិងសុខភាពសត្វ ជាអនុវិស័យមួយយ៉ាងសំខាន់នៃវិស័យកសិកម្ម ក្នុងការចូលរួមចំណែកអនុវត្តយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣របស់រាជរដ្ឋាភិបាលកម្ពុជា ហើយការងារនេះបាននិងបន្តចាត់ទុកជាផ្នែកអាទិភាពមួយទៀត សំដៅចូលរួមចំណែកបង្កើនផលិតភាពសត្វ បង្កើតការងារ និងបង្កើនប្រាក់ចំណូលជូនប្រជាកសិករនៅតាមជនបទ កាត់បន្ថយភាពក្រីក្រ និងកំណើនជីវភាពគ្រួសារឲ្យមានភាពធូរធា ដោយបន្តការគាំទ្រនិងពង្រឹងសន្តិសុខស្បៀង ផ្តល់អាហារូបត្ថម្ភគ្រប់គ្រាន់ និងសុវត្ថិភាពម្ហូបអាហារសម្រាប់តម្រូវការក្នុងស្រុកនិងការនាំចេញស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល។

ក្នុងឆ្នាំ២០១៣អង្គភាពជំនាញបានខិតខំអនុវត្តកម្មវិធីជាអាទិភាពក្នុងផ្នែកផលិតកម្មសត្វនិងសុខភាពសត្វស្របតាមគោលនយោបាយជាតិរួមមាន ៖ (១) ការកសាងច្បាប់ និង អភិវឌ្ឍធនធានមនុស្សក្នុងផ្នែកផលិតកម្មសត្វ និងសុខភាពសត្វ (២) ការកាត់បន្ថយអត្រាសត្វឈឺនិងងាប់ ដោយធ្វើការជំរុញនូវវិធានបសុពេទ្យ (៣) ការធ្វើឱ្យប្រសើរឡើងនូវសុខភាពសាធារណៈ ពិសេសជំងឺឆ្លងពីសត្វទៅមនុស្ស និងសុវត្ថិភាពម្ហូបអាហារមានប្រភពពីសត្វ (៤) ជំរុញធ្វើឱ្យប្រសើរឡើងនូវផលិតកម្មចំណីសត្វ និងពូជសត្វ (៥) ជំរុញការកែច្នៃលាមកសត្វ តាមរយៈការបង្កើតឡជីវឧស្ម័ន (៦) ជំរុញការកែទម្លាប់ការចិញ្ចឹមសត្វរបស់កសិករពីលក្ខណៈគ្រួសារ ទៅជាបែបពាណិជ្ជកម្មដោយមានជីវសុវត្ថិភាពនៅកន្លែងមានឡជីវឧស្ម័ន (៧) បង្កើននិងពង្រឹងការស្រាវជ្រាវ និងផ្សព្វផ្សាយលើការងារផលិតកម្មសត្វនិងសុខភាពសត្វ (៨) ជំរុញឱ្យប្រសើរឡើងនូវគុណភាពក្នុងការសាងសង់ឡជីវឧស្ម័ននិងការចិញ្ចឹមសត្វ និង(៨) លើកទឹកចិត្តការវិនិយោគលើការចិញ្ចឹមសត្វ សេវាសុខភាពសត្វ និងធ្វើឱ្យប្រសើរឡើងនូវទីផ្សារសត្វ និងផលិតផលមានដើមកំណើតពីសត្វ។

ឆ្នាំ២០១៣ នៅទូទាំងប្រទេសមានគោក្របីសរុបជាង ៤,០៥លានក្បាល (គោក្របីចំនួន ៦៣៧.០០០ក្បាល សម្រាប់ពិឃាត និងនាំចេញប្រមាណ ១៩.៧០៨ក្បាល)។ ជ្រូកមានចំនួនជាង ២,៤លានក្បាល ដែលផលិតចេញជាជ្រូកសាច់បានចំនួន២.៤០០.០០០ក្បាល សម្រាប់ផ្គត់ផ្គង់សាច់ទីផ្សារក្នុងស្រុក និងនាំចេញបានចំនួន ១២.១០២ក្បាល។ ដោយឡែកបក្សីមានចំនួនជាង២៧លានក្បាល ផលិតសាច់បានប្រមាណ២៦,៦លានក្បាល សម្រាប់ផ្គត់ផ្គង់តម្រូវការក្នុងស្រុក។ ជារួមផលិតផលសាច់សត្វមានប្រមាណ ២៦២.០០០ តោន/ឆ្នាំ។

ការចិញ្ចឹមសត្វមានរូបភាពជាលក្ខណៈគ្រួសារ និងលក្ខណៈពាណិជ្ជកម្មកសិដ្ឋានខ្នាតតូច និងខ្នាតធំ។ គ្រប់រូបភាពនៃការចិញ្ចឹមសត្វខាងលើ ជាពិសេសការចិញ្ចឹមសត្វជាលក្ខណៈគ្រួសារគឺប្រែប្រួលបន្តិចម្តងៗពីការចិញ្ចឹមសត្វជាយថាផលទៅជាការចិញ្ចឹមសត្វបែបអាទិផល ដោយយកចិត្តទុកដាក់លើបច្ចេកទេសចិញ្ចឹម បង្កាត់ពូជ និងការជ្រើសរើសពូជ ការផ្តល់ចំណី ប្រសិទ្ធភាពសេដ្ឋកិច្ច និងជាពិសេសការផ្លាស់ប្តូរពីការផលិតសម្រាប់ផ្គត់ផ្គង់ខ្លួនឯងទៅជាការផលិតដើម្បីធ្វើពាណិជ្ជកម្ម។ វឌ្ឍនភាពនៃការចិញ្ចឹមដែលកត់សម្គាល់គឺការវិនិយោគទុនលើការបង្កើតរោងចក្រផលិតចំណីសត្វដែលបច្ចុប្បន្នមានចំនួន៧កន្លែង និងអាចផលិតចំណីសត្វផ្សំស្រេចប្រមាណ១លានតោន/ឆ្នាំ។ បរិមាណចំណីសត្វផ្សំស្រេចនៅមិនទាន់ផ្គត់ផ្គង់គ្រប់គ្រាន់តាមតម្រូវការទីផ្សារក្នុងស្រុកនៅឡើយ ដោយត្រូវការវិនិយោគទុនបន្ថែមទៀត ជាពិសេសសប្រភេទចំណីផ្សំស្រេចសម្រាប់កូនជ្រូកដែលចំណីទាំងនេះមានប្រូតេអ៊ីនកម្រិតខ្ពស់។

ដោយមានការរីកចម្រើនលើវិស័យផលិតកម្មសត្វ និងដើម្បីគ្រប់គ្រងកាកសំណល់សត្វនិងការពារផលប៉ះពាល់បរិស្ថានក៏ដូចជាកាត់បន្ថយការឡើងកម្តៅនៃភពផែនដី ក្រសួងបានរៀបចំកម្មវិធីឡជីវឧស្ម័នដោយបង្កើតឡជីវឧស្ម័នបាន២០.២៨៨ឡ នៅទូទាំងប្រទេស ក្នុងនោះបង្កើតបានចំនួន១.១១៥ឡ នៅឆ្នាំ២០១៣។ ឡជីវឧស្ម័នបានប្រមូលលាមកសត្វដើម្បីបង្កើតបានជាឧស្ម័នមេតានសម្រាប់ជាប្រភពថាមពល ជាពិសេសសម្រាប់ដាំស្ល កែច្នៃ និងធ្វើឲ្យប្រសើរឡើងនូវជីលាមកសត្វ បង្កើនប្រសិទ្ធភាពជីវសុវត្ថិភាពសត្វ និងជាកន្លែងចិញ្ចឹមសត្វគំរូដែលមានអនាម័យនិងសុវត្ថិភាព។

នៅឆ្នាំ២០១៣ ជំងឺឆ្លងរាលដាលសត្វក៏គ្រប់គ្រងបានល្អ ទោះបីជាមានស្ថានភាពទឹកជំនន់ធ្ងន់ធ្ងរក្តី។ អត្រាឈឺស្លាប់សត្វតិចជាង២% ដោយឡែកជំងឺផ្តាសាយបក្សីក៏ត្រូវបានបង្ការ និងទប់ស្កាត់បានទាន់ពេលវេលាមិនឲ្យមានការឆ្លងរាលដាលខ្លាំងក្លា។ ប៉ុន្តែទោះបីយ៉ាងនេះក្តី ក៏ចាំបាច់ត្រូវចុះអង្កេត ស្រាវជ្រាវ តាមដានជំងឺឆ្លងសត្វជាប្រចាំ និងទទួលខុសត្រូវខ្ពស់ ដោយសហការជាមួយស្ថាប័នពាក់ព័ន្ធនិងអាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់។

ស្ថានភាពសុខភាពសាធារណៈបសុព្យាបាលក៏ត្រូវបានយកចិត្តទុកដាក់ខ្ពស់ និងមានការវិវឌ្ឍន៍ជាវិជ្ជមានដោយបានបង្កើតសត្តឃាតដ្ឋានដែលមានកន្លែងពិឃាតសត្វសមរម្យ និងមានភ្នាក់ងារបសុពេទ្យប្រចាំការត្រួតពិនិត្យសាច់ផលិតផលសត្វ នៅសត្តឃាតដ្ឋានចំនួន១២១កន្លែងនៅទូទាំងប្រទេស មានសត្តឃាតដ្ឋានពិឃាតសត្វទំនើបសម្រាប់ពិឃាតបក្សីនិងកែច្នៃផលិតផលសាច់។ សាច់សត្វ ស៊ុត និងផលិតផលសត្វត្រូវបានត្រួតពិនិត្យអនាម័យ និងធានានូវគុណភាព សុវត្ថិភាព អនុវត្តតាមបទ្រឹស្តី «សុវត្ថិភាពពីកសិដ្ឋានដល់តុបរិភោគ» ដោយហេតុថា បានធ្វើការត្រួតពិនិត្យបច្ចេកទេសនិងអនាម័យចាប់ពីកន្លែងនិងកសិដ្ឋានចិញ្ចឹមសត្វ ត្រួតពិនិត្យពេលដឹកជញ្ជូន ត្រួតពិនិត្យនៅទីសត្តឃាតដ្ឋាននិងរហូតដល់កន្លែងតាំងលក់។

ការស្រាវជ្រាវលើការងារផលិតកម្មសត្វនិងសុខភាពសត្វក៏ត្រូវបានយកចិត្តទុកដាក់ ជាពិសេសទំនើបកម្មក្នុងការធ្វើរោគវិនិច្ឆ័យជំងឺសត្វក៏ដូចជាការធ្វើឲ្យមានការទទួលស្គាល់ជាលក្ខណៈអន្តរជាតិ នៃមន្ទីរពិសោធន៍រោគវិនិច្ឆ័យជំងឺសត្វរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។ ច្បាប់ លិខិតបទដ្ឋានគតិយុត្ត សម្រាប់វិស័យផលិតកម្មនិបសុព្យាបាល ក៏ត្រូវបានយកចិត្តទុកដាក់ខ្ពស់និងត្រូវបានរៀបចំ។ សេចក្តីព្រាងច្បាប់ស្តីពីសុខភាពសត្វនិងផលិតកម្មសត្វត្រូវបានដាក់ឆ្លងពិនិត្យនិងពិភាក្សានៅទីស្តីការគណៈរដ្ឋមន្ត្រី និងរង់ចាំការអនុម័តពីគណៈរដ្ឋមន្ត្រីដើម្បីបញ្ជូនទៅរដ្ឋសភានិងព្រឹទ្ធសភា ដើម្បីបញ្ចប់ឲ្យបានទាន់ពេលវេលាក្នុងនាម កម្ពុជាជាសមាជិកមួយនៃអង្គការពាណិជ្ជកម្មពិភពលោក។

ដោយឡែកការផ្សព្វផ្សាយច្បាប់ លិខិតបទដ្ឋានគតិយុត្តវិស័យផលិតកម្មនិងបសុព្យាបាល ក៏ដូចជាការផ្សព្វផ្សាយព័ត៌មានបច្ចេកទេសផលិតកម្មនិងបសុព្យាបាលក៏បានអនុវត្តយ៉ាងទូលំទូលាយក្នុងចំណោមអង្គភាពផលិតកម្មនិងបសុព្យាបាល ស្ថាប័ន អាជ្ញាធរពាក់ព័ន្ធគ្រប់លំដាប់ថ្នាក់ កសិករ និងផ្នែកឯកជន។ រីឯភ្នាក់ងារសុខភាពសត្វភូមិក៏ត្រូវបានពង្រឹងដើម្បីធានាការផ្សារភ្ជាប់ជាមួយប្រជាកសិករឲ្យបានកាន់តែជិតស្និទ្ធថែមទៀត។

## ៤ ផ្នែកព្រៃឈើ

### ៤.១ ការអនុវត្តគោលនយោបាយកំណែទម្រង់វិស័យព្រៃឈើឆ្នាំ២០១៣៖

#### ៤.១.១- ការកំណត់ព្រំប្រទល់និងសារពើភ័ណ្ឌ

ក្នុងឆ្នាំ២០១៣កន្លងមកនេះ រដ្ឋបាលព្រៃឈើបានបោះបង្គោលព្រំប្រទល់ដែនព្រៃបម្រុងទុកអចិន្ត្រៃយ៍សម្រេចតាមផែនការដែលដាក់ចុះចំនួន ៤៦៧បង្គោល លើដីប្រវែង៧៥ គីឡូម៉ែត្រ ដោយបានបញ្ចប់១០០%នៅក្នុងខណ្ឌទាំង៥ រួមមាន ខណ្ឌរដ្ឋបាលព្រៃឈើកណ្ដាល ៩១បង្គោល កំពត ១០៣បង្គោល ក្រចេះ ៩១បង្គោល មណ្ឌលគិរី ៩១បង្គោល និងឧត្តរមានជ័យ ៩១បង្គោល។ ការបោះបង្គោលព្រំនៅទូទាំងប្រទេសមកទល់ពេលនេះសរុបចំនួន១៧.៧១៧បង្គោល លើដីប្រវែង ២.៥៨៦គីឡូម៉ែត្រ។ ទន្ទឹមនឹងនេះក៏បានកែសម្រួលបញ្ចប់១០០%លើឯកសារបច្ចេកទេសបកស្រាយផ្កាយរណបនិងការប្រើប្រាស់ឧបករណ៍ទីជម្រាលសម្រាប់ធ្វើសារពើភ័ណ្ឌរៀបចំដោយជំនាញការជប៉ុន ហើយបានធ្វើការវាយតម្លៃគម្របព្រៃឈើលើរូបភាពផ្កាយរណប Landsat 2005 និង Landsat 2010 ព្រមទាំងបានធ្វើការវាយតម្លៃប៉ាន់ស្មានធនធានព្រៃឈើលើដីសម្បទានសេដ្ឋកិច្ចចំនួន២៨ ក្រុមហ៊ុន។

#### ៤.១.២- សហគមន៍ព្រៃឈើ

-សហគមន៍ព្រៃឈើចំនួន៤៦កន្លែងត្រូវបានចុះកិច្ចព្រមព្រៀងលើផ្ទៃដី៦២.០៤៨ហិកតា ក្នុងនោះខេត្តព្រះវិហារ ៨កន្លែង មានផ្ទៃដី១៥.៣៤៧ហិកតា ហើយសហគមន៍ព្រៃឈើចំនួន៥៤កន្លែងផ្សេងទៀតមានផ្ទៃដី ៥៨.៤៥៧ហិកតា ស្ថិតនៅក្នុង១០ខេត្តដែលក្រសួងបានចេញប្រកាសស្ដីពីការបង្កើត និងគ្រប់គ្រងតំបន់ព្រៃសហគមន៍ទាំងនោះរួចហើយ។ ជាមួយគ្នានេះ ក្រសួងនឹងរៀបចំពិនិត្យជាបន្តលើសេចក្ដីព្រាងប្រកាសស្ដីពីការបង្កើតនិងការ គ្រប់គ្រងតំបន់ព្រៃសហគមន៍ចំនួន១៥កន្លែងទៀតដែលមានផ្ទៃដីចំនួន២១.០២៤ហិកតាក្នុងខេត្តចំនួន៨។ សរុបទូទាំងប្រទេសមានសហគមន៍ព្រៃឈើចំនួន៤៥៧សហគមន៍ និងមានផ្ទៃដី២៤៩ ១៤២ហិកតា

-បានចុះពិនិត្យការអនុវត្តគម្រោង SFM ដែលអនុវត្តដោយអង្គការ RECOFTS ម្ជប់បែកង និងអង្គការ Geres នៅខេត្តពោធិ៍សាត់ កំពង់ឆ្នាំង កំពង់ស្ពឺ និងខេត្តបាត់ដំបង។ ទន្ទឹមនឹងនេះក៏មានរៀបចំប្រឡងជ្រើសរើស សហគមន៍ព្រៃឈើឆ្នើមប្រចាំឆ្នាំ២០១២ ក្រោមប្រធានបទ « ការគ្រប់គ្រងព្រៃសហគមន៍ដោយនិរន្តរភាព » ដើម្បីចូលរួមសន្និបាតកសិករលើកទី៤ឆ្នាំ២០១៣ ហើយជាលទ្ធផលជ្រើសរើសបានសហគមន៍ឆ្នើម៥កន្លែងដែលបានទទួលជ័យលាភី រួមមាន នៅខេត្តកំពង់ស្ពឺ ឧត្តរមានជ័យ កំពង់ធំ សៀមរាប និងខេត្តពោធិ៍សាត់

-បានធ្វើបច្ចុប្បន្នភាពទិន្នន័យសហគមន៍ព្រៃឈើតាមបណ្ដាខណ្ឌរដ្ឋបាលព្រៃឈើ ហើយបានបោះពុម្ពសៀវភៅស្ថិតិសហគមន៍ព្រៃឈើកម្ពុជាប្រចាំឆ្នាំ២០១៣ បានចំនួន ៥.០០០ក្បាល។

#### ៤.១.៣ ការប្រមូលចំណូលពីវិស័យព្រៃឈើ (គិតចាប់ពីខែមករា ដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៣)

-ចំណូលបានមកពីវិស័យព្រៃឈើសរុបចំនួន ៦៣.៣២២.៦៧៤.២៤០រ០០ ស្មើនឹង ២៩៥.២៧% នៃផែនការ ក្នុងនោះចំណូលបានមកពីថ្លៃសួយសារផល អនុផលព្រៃឈើចំនួន៥៣.៣៧៩.៧៩៥.១០០រ០០ និងពីការផាកពិន័យ និងលក់ឡាយឡុងនូវផល អនុផលព្រៃឈើចំនួន ៩.៩៤២.៨៧៩.១៤០រ០០។ បើប្រៀបធៀបនឹងឆ្នាំ២០១២ឃើញថា ចំណូលមានការកើនឡើងប្រហែល ១៥៥.៦០% (ចំណូលឆ្នាំ២០១២មាន៣៣.៤០៥.៤២៣.៨១១៦រៀល)។

#### ៤.១.៤ ការដេញថ្លៃផល អនុផលព្រៃឈើជាសាធារណៈ

ជាលទ្ធផលក្នុងឆ្នាំ២០១៣នេះរដ្ឋបាលព្រៃឈើជាសេនាធិការបានធ្វើការពិគ្រោះថ្លៃផល-អនុផលព្រៃឈើ ដែលបានពីការរឹបអូសតាមរយៈសាលក្រមតុលាការឈើអញ្ញាតជន ឈើពិន័យអន្តរការណ៍សរុបចំនួន០២លើកស្មើនឹងឈើចម្រុះប្រភេទចំនួន៥.០១៣ម៣១៨៩។

#### ៤.១.៥ ការដាំឈើនិងស្ដារព្រៃឈើ

-ការដាំឈើនៅតាមស្ថានីយ៍ផ្សព្វផ្សាយ និងស្ដារព្រៃឈើរបស់រដ្ឋបាលព្រៃឈើដោយបានបណ្ដុះកូនឈើចំនួនប្រមាណ៩៩០.០០០ដើម និងដាំតាមទីតាំងនានាចំនួន៣២០ហិកតា

-ក្រុមហ៊ុនដីសម្បទានសេដ្ឋកិច្ចដាំកូនឈើនិងកូនកៅស៊ូបានចំនួនប្រមាណ១៦.៦៦៥ហិកតា ឈូសឆាយបានចំនួន២៣.២៦២ហិកតា

-ផ្នែកឯកជនខ្នាតតូច/គ្រួសារបណ្ដុះកូនឈើបានចំនួនប្រមាណ១.៦០០.៤០០ដើម។ ថ្នាលបណ្ដុះកូនឈើ

របស់រដ្ឋបាលព្រៃឈើទាំងអស់បណ្តុះកូនឈើបានចំនួនប្រមាណ៤.២០៩.៩៤៥ដើមនិងចែកចាយកូនឈើជូនប្រជាពលរដ្ឋចំនួន២.១៨៦.៩០៤ដើម

-ការងារដាំឈើជាចម្ការរបស់ក្រុមហ៊ុនដៃគូមានក្រុមហ៊ុន Think Biotech (Cambodia) ឈូសឆាយបាន ៧៦០ហិកតា បណ្តុះកូនឈើបានប្រមាណ២.២៥០.០០០ដើម(គ្រញូងនិងអាកាស្យា) និងដាំលើផ្ទៃដីបាន៧៦០ហិកតា រីឯក្រុមហ៊ុន Oji (Cambodia) Plantation ឈូសឆាយបាន៨៥ហិកតា បណ្តុះកូនឈើបាន ៦៥០.០០០ដើម (អាកាស្យា) និងដាំលើផ្ទៃដីបាន៨៥ហិកតា

-បុណ្យរុក្ខទិវាថ្នាក់ជាតិ ៩កក្កដា ២០១៣ បានរៀបចំនៅភូមិ១ឃុំអូរត្រេះស្រុកស្ទឹងហាវ ខេត្តព្រះសីហនុ លើផ្ទៃដីទំហំ២០ហិកតា ក្រោមព្រះរាជាធិបតីភាពដ៏ខ្ពង់ខ្ពស់បំផុតរបស់ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា។ នៅតាមរាជធានី ខេត្តទាំង២៤ ខណ្ឌរដ្ឋបាលព្រៃឈើបានរៀបចំប្រារព្ធពិធីបុណ្យរុក្ខទិវាថ្នាក់ខេត្ត លើផ្ទៃដីសរុបជាង៥២ហិកតា និងមានប្រជាពលរដ្ឋចូលរួមប្រមាណ ១១.៥០០នាក់។

**៤.១.៦ ការងារស្រាវជ្រាវ និងបណ្តុះបណ្តាល**

បានសហការជាមួយដៃគូអភិវឌ្ឍន៍មួយចំនួនដូចជាADB, JICA, FFPRI/Japan, Kyushu university/ Japan, AusAID, APFNet/China, UN-REDD Program Cambodia, AKECOP/Korea, AFoCO/Korea, and FAO ក្នុងការងារពង្រឹងការងារស្រាវជ្រាវដែលមានថវិកាសរុបចំនួន៩០០.៦១៧,៧០ដុល្លារអាមេរិកក្នុងការអនុវត្តគម្រោងចំនួន១៤។ ជាមួយគ្នានេះវិទ្យាស្ថានបាននឹងកំពុងលើកគម្រោងស្នើសុំពីដៃគូបន្ថែមទៀតពី (ITTO (3Years), AFoCO /Korea(10ឆ្នាំ)កម្មវិធីLandmark Program) ដែលមានថវិកាសរុបចំនួន៣.៤៦៦.៨០០ដុល្លារអាមេរិក។

**៤.១.៧ ការពង្រឹងការងារអនុវត្តច្បាប់ស្តីពីព្រៃឈើ**

បានទទួលសំណុំរឿងបទល្មើសព្រៃឈើដើម្បីពិន័យអន្តរការណ៍ និងច្បាប់ចម្លងសំណុំរឿងបទល្មើសព្រៃឈើដែលបានបញ្ជូនទៅតុលាការសរុបចំនួន១.៥២៣ករណី (បើប្រៀបធៀបឆ្នាំ២០១២ មានចំនួនតែ១.០៩៩ករណីកើនឡើង៤២៤ករណីស្មើនឹង៤២%)ក្នុងនោះមានវត្ថុតាងបទល្មើសព្រៃឈើនិងសត្វព្រៃបានចាប់យាត់និងដកហូតរួមមានឈើមូលចំនួន៥៧០ម៣ ឈើអារ៤.០៨០ម៣ ឈើប្រង១៥១ម៣ ឈើក្រាក់គ្រញូង២២ម៣និង៩.២០៤គ.ក្រ កូនឈើ ២.៦៥២ដើម និងអនុផលព្រៃឈើមួយចំនួនទៀត។ រីឯមធ្យោបាយប្រព្រឹត្តបទល្មើសដែលបានឃាត់ទុករួមមានរថយន្ត ៦១៧គ្រឿង អេស្កាវ៉ាទ័រ០៤គ្រឿង ត្រាក់ទ័រ១៣គ្រឿង និងមធ្យោបាយផ្សេងៗសរុបចំនួន៣១២គ្រឿង។ ចំពោះបទល្មើសដីព្រៃ មន្ត្រីរដ្ឋបាលព្រៃឈើបានចុះស្រង់ស្ថិតិការកាប់រានដីព្រៃចំនួន១៧២.១ហិកតា និងដកហូតដីព្រៃឈើដែលបានកាប់រានចំនួន១.៨៦៤ហិកតា និងដកហូតរណារយន្ត១៤៤គ្រឿង។

## ៤.២ ការងារអភិរក្សធនធានជីវចម្រុះនិងសត្វព្រៃ

-ធ្វើការកត់ត្រាសត្វស្លាបនៅតាមតំបន់អភិរក្សសត្វស្លាបសំខាន់ៗចំនួន៤(អាងត្រពាំងថ្ម បឹងព្រែកល្ពៅ កំពង់ធំ-សៀមរាប និងអន្លង់ព្រីង) ដែលមានសត្វស្លាបចំនួន២១៥ប្រភេទ (ប្រមាណ៥៥.២២៨ក្បាល)។ ចំពោះប្រភេទត្មាតចំនួនជាង២០០ក្បាល ត្រយ៉ងប្រមាណ៩៧៤ក្បាល ខ្សឹបប្រមាណ៩៣៥ក្បាល និងសត្វក្រៀលប្រមាណ៨៤០ក្បាល

-រៀបចំអាហារដ្ឋានត្មាតចំនួន២២លើក នៅតំបន់វាលបឹងទាល់នៃព្រៃការពារព្រះវិហារ នៅតំបន់ព្រៃការពារមណ្ឌលគិរី សៀមប៉ាង និងនៅតំបន់ស្រែព្រៃ ខេត្តក្រចេះ ដែលមានត្មាតសរុបជាង២០០ក្បាល

-ការពារសម្បុកសត្វត្រដក់តូចចំនួន៩៧ និងត្រយ៉ងចង្កំ ក សចំនួន៣៦ ត្រយ៉ងយក្សចំនួន១៧ ត្មាតចំនួន១៣ ទាព្រៃស្លាបសចំនួន១ និងរំពេទន្លេចំនួន១០ សម្បុកនៅក្នុងព្រៃការពារព្រះវិហារ ព្រៃការពារមណ្ឌលគិរី តំបន់ទន្លេមេគង្គលើនិងសៀមប៉ាង

-ប្រមូលយកកូនក្រពើទើបញាស់ចំនួន៣៣ក្បាលពីស្ទឹងអារ៉ែង ឃុំជំនាប់ ស្រុកថ្មបាំង ខេត្តកោះកុង មកថែបំប៉ននៅស្នាក់ការល្បាតអារ៉ែងរបស់រដ្ឋបាលព្រៃឈើក្នុងឃុំថ្មដូនពៅ ស្រុកថ្មបាំង ខេត្តកោះកុង រង់ចាំការដោះលែងចូលបឹងធម្មជាតិ

-ការងារនៅឧទ្យានសួនសត្វនិងមជ្ឈមណ្ឌលសង្គ្រោះសត្វព្រៃភ្នំតាម៉ៅកំពុងចិញ្ចឹម និងថែរក្សាសរុបចាប់ពីដើមឆ្នាំ សត្វចំណូលថ្មីចំនួន៧៨២ក្បាល សត្វកើតថ្មីចំនួន៦៧ក្បាល សត្វដោះលែងចំនួន៥២៤ក្បាល សត្វស្លាប់ចំនួន១៥៥ក្បាល ព្យាបាលសត្វចំនួន២៧៦ក្បាល យកសំណាកទៅពិសោធន៍ចំនួន៣០៤ក្បាល ធ្វើឲ្យសន្លប់ចំនួន១៨៩ក្បាល ទម្លាក់សត្វល្អិតចំនួន៦៤១ក្បាល វះកាត់សាកសពសត្វចំនួន៥១ក្បាល ដាក់លេខកូដចំនួន២៥ក្បាល ចាក់វ៉ាក់សាំងចំនួន

៧៨៦ក្បាល សាងសង់របងហ៊ុមព័ទ្ធនិងទ្រុងសត្វថ្មីលើដីចំនួន១៣.៨៨៨ម² សាងសង់ទ្រុងសត្វនិងអគារផ្សេងៗចំនួន ៣.៦៤៧ម² ជួសជុលផ្លូវចំនួន៣៦៥.៨៨៣ម² សាងសង់សំណង់ផ្សេងៗចំនួន១.២០៧ម² ថ្លារអនាម័យព្រៃចំនួន ២៤៤.១៨៤ម² ដាំកូនឈើចំនួន១.៥៨៤ដើម បណ្តុះផ្កាលម្អ(ផ្កាក្រដាស)ចំនួន៥.១២៣ដើម និងអប់រំផ្សព្វផ្សាយដល់សិស្សានុសិស្សបានចំនួន១១.៨៦៣នាក់

-ក្រុមហ៊ុនចំនួន០៧ កំពុងចិញ្ចឹមស្វាក្តាមមេ-បាពូជ និងកូនស្វាក្តាមចំនួន៥៧.៩៩៧ក្បាល។

## ៥ ផ្នែកជលផល

នៅក្នុងឆ្នាំ២០១៣ នេះ រដ្ឋបាលជលផលបានបំពេញភារកិច្ចយ៉ាងសកម្ម ដោយសម្រេចបានលទ្ធផលគ្រប់ផ្នែកលើវិស័យជលផល ក្នុងនោះមានការរៀបចំកែសម្រួលលិខិតបទដ្ឋានក្រោមច្បាប់ ការពង្រឹងសហគមន៍នេសាទ ការបង្កើតស្រះជម្រកត្រី ការអភិវឌ្ឍន៍វារីវប្បកម្ម ការសិក្សាស្រាវជ្រាវ ការអភិរក្ស ការបង្ក្រាបបទល្មើសនេសាទ និងការផ្សព្វផ្សាយជាដើម។ ដោយឡែក ព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាស និងបទដ្ឋានបច្ចេកទេសមួយចំនួនទៀតដែលបានរៀបចំត្រូវបានពិនិត្យ កែសម្រួល និងអនុម័ត ដើម្បីដាក់ឱ្យអនុវត្តធានាដល់ការគ្រប់គ្រងវិស័យជលផលប្រកបដោយប្រសិទ្ធភាព ។

ការកែទម្រង់ស៊ីជម្រៅវិស័យជលផលដំណាក់កាលទី២ រាជរដ្ឋាភិបាលបានសម្រេចលុបឡូត៍នេសាទទាំងអស់ទុកសម្រាប់ប្រជាពលរដ្ឋធ្វើនេសាទជាលក្ខណៈគ្រួសារ និងធ្វើជាកន្លែងអភិរក្សជលផល។

លទ្ធផលសម្រេចបានមានខ្លឹមសារសង្ខេបដូចតទៅ៖

១. លទ្ធផលសម្រេចបានផ្នែកជលផល

ផលត្រីសរុបមានចំនួនប្រមាណ៧១៨.០០០តោន កើនលើសឆ្នាំមុនចំនួន៣៦.០០០តោន ក្នុងនោះមាន៖

- ផលនេសាទទឹកសាប: ៥២៨.០០០តោន
- ផលនេសាទសមុទ្រ: ១០០.០០០តោន
- ផលវារីវប្បកម្ម: ៩០.០០០តោន

២. ការអភិវឌ្ឍន៍វារីវប្បកម្ម

ការចិញ្ចឹមត្រីអនុវត្តបានប្រមាណ៩០.០០០តោន បើប្រៀបធៀបឆ្នាំកន្លងទៅកើន១៦.០០០តោន

-កន្លែងភ្ញាស់ត្រីសរុបមានចំនួន២៩៨កន្លែង ដែលក្នុងនោះមាន២៨៥កន្លែងជារបស់ប្រជាពលរដ្ឋ តាមរយៈការផ្តល់បច្ចេកទេសពីមន្ត្រីរដ្ឋបាលជលផល

-ផលិតកូនត្រីពូជសរុបចំនួនប្រមាណ១៥០លានក្បាល កើនលើសឆ្នាំកន្លងទៅប្រមាណ១០លានក្បាល ដែលក្នុងនោះមានកូនបង្កងចំនួនប្រមាណ១លានក្បាល

-មានប្រជាពលរដ្ឋប្រមាណ៦០.០០០គ្រួសារ បានចូលរួមក្នុងសកម្មភាពចិញ្ចឹមត្រី ដោយបានទទួលការបណ្តុះបណ្តាលពីបច្ចេកទេសចិញ្ចឹមត្រីជាបន្តបន្ទាប់ ក្នុងនោះមានកសិករ១៩៤នាក់ ជាគ្រូបង្គោល និងជាគ្រូផ្សព្វផ្សាយនៅមូលដ្ឋាន។

៣. ការបង្កើតស្រះជម្រកត្រីសហគមន៍

អនុវត្តតាមអនុសាសន៍របស់សម្តេចតេជោ កាលពីឆ្នាំ២០០៩ នៅខេត្តកែប មន្ត្រីរដ្ឋបាលជលផល គ្រប់ខេត្តបានបង្កើតស្រះជម្រកត្រីសហគមន៍បាន៧៦៦កន្លែង គិតរហូតដល់ចុងឆ្នាំ២០១៣នេះ ហើយដែលនៅខេត្តកំពង់ស្ពឺមានចំនួនច្រើនជាងគេរហូតដល់១៧៣កន្លែង។ សកម្មភាពនេះ ក៏បានធ្វើឲ្យផលត្រីតាមវាលស្រែកើនឡើងប្រមាណពី៤ទៅ៦ដងផងដែរ។

៤. ការអភិវឌ្ឍន៍បច្ចេកវិទ្យាកែច្នៃនិងគុណភាព

ជាការងារថ្មីដែលរដ្ឋបាលជលផលកំពុងពន្យល់និងផ្សព្វផ្សាយ ដើម្បីឲ្យគ្រប់កន្លែងផលិត និងកែច្នៃត្រីងាយគោរពទៅតាមស្តង់ដារអនាម័យឲ្យបានត្រឹមត្រូវ ក្នុងន័យធានាសុខភាពសាធារណៈនិងទីផ្សារនាំចេញ ដោយរួមទាំងសកម្មភាពភូមិ១ផលិតផលជលផល១ផងដែរ។

៥. កំណែទម្រង់វិស័យជលផល

ការកែទម្រង់ស៊ីជម្រៅវិស័យជលផលបានលុបឡូត៍នេសាទចំនួន១៥៨ឡូត៍ ដែលមានផ្ទៃឡូត៍សរុប ៩៥៣.៨៦១ហិកតា ក្នុងនោះបានកាត់ជូនប្រជាពលរដ្ឋចំនួន៨៥៦.៣៥៨ហិកតា ស្មើនឹង៨៩,៧៧% និងរក្សាទុកកន្លែងអភិរក្សជលផលចំនួន៩៧.៥០៣ហិកតា ស្មើនឹង១០,២៣%។

## ៦. ការអភិវឌ្ឍន៍សហគមន៍នេសាទ

រហូតមកដល់ឆ្នាំ២០១៣នេះ យើងបង្កើតសហគមន៍នេសាទបានចំនួន៥១៦ ក្នុងនោះសហគមន៍នេសាទទឹកសាបចំនួន៤៧៧ និងសហគមន៍នេសាទសមុទ្រ៣៩។ ក្នុងចំណោមសហគមន៍ខាងលើនេះ មានសហគមន៍នេសាទចំនួន៣៦០ ត្រូវបានចុះបញ្ជីទទួលស្គាល់ជាផ្លូវការដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រួចហើយ។

ដោយឡែក ការបង្កើតធនាគារក្តាមមានចំនួន៣២កន្លែងស្មើនឹង៩៥បែ ដែលក្នុងឆ្នាំ២០១៣នេះ បានលែងមេក្តាមពងចំនួន៦.៣៥៦គ.ក្រ (ប្រមាណ៥៣.៤០៦ក្បាល)។ បើគិតពីឆ្នាំ២០០៨មកដល់បច្ចុប្បន្ន គឺបានលែងមេក្តាមចំនួន៣៥.៧៦២គ.ក្រ (ប្រមាណ២៥៩.៤៩៨ក្បាល) ដែលបានផ្តល់កូនក្តាមចំនួនប្រមាណ២០៧.១៦៣លានក្បាលចូលទៅក្នុងសមុទ្រវិញ។ សកម្មភាពនេះ តាមការស្រាវជ្រាវរបស់វិទ្យាស្ថានឃើញថា បានធ្វើឲ្យផលក្តាមសេះមានកំណើនប្រមាណ៤ដងបើប្រៀបធៀបមុនពេលបង្កើតធនាគារក្តាម។

## ៧. ការអភិរក្សធនធានជលផល

ក្រោយការកែទម្រង់ស៊ីជម្រៅវិស័យជលផលគឺបាន រំសាយឡូត៍នេសាទទាំងអស់នៅទូទាំងប្រទេសដោយមានកន្លែងអភិរក្សជលផលថ្មីចំនួន៥៨កន្លែង ដែលមានទំហំសរុប១២០.០០៣ហិកតា។ ក្នុងឆ្នាំ២០១៣នេះ បានបោះបង្គោលកញ្ចូមបេតុងបានចំនួន៣២ដើម និងសាងសង់ស្នាក់ការបណ្តែតទឹកបានចំនួន៤ ព្រមទាំងបានដាក់កម្លាំងយាមល្បាតជាប្រចាំ។ សកម្មភាពអភិរក្សជលផលផ្សេងៗទៀតមានដូចតទៅ៖ អភិរក្សថ្កា ស្មៅសមុទ្រចំនួន៣.៨៣១ហិកតា នៅតាមតំបន់ឆ្នេរ ដាំព្រៃលិចទឹកនិងព្រៃកោងកាងបានចំនួន១០០ហិកតា រៀបចំអន្លង់ត្រីមេពូជបានចំនួន១៨កន្លែងនៅតំបន់មេគង្គលើ និងបានលែងកូនត្រីនិងកូនបង្កងចំនួនប្រមាណ៥.០០០.០០០ក្បាល ទៅក្នុងបឹងធម្មជាតិ។

## ៨. ការបង្ក្រាបបទល្មើសជលផល

អនុវត្តតាមបទបញ្ជា០១ បប ជាបង្អែក មន្ត្រីរដ្ឋបាលជលផលគ្រប់លំដាប់ថ្នាក់បានសហការជាមួយអាជ្ញាធរដែនដី និងសមត្ថកិច្ចពាក់ព័ន្ធខិតខំបំពេញការងារយ៉ាងសកម្ម ទោះបីខ្វះកម្លាំង មធ្យោបាយធ្វើដំណើរ និងថវិកាក៏ដោយ ជាពិសេសបានយកចិត្តទុកដាក់ការពារកន្លែងអភិរក្សជលផលមិនឲ្យមានការលួចចូលធ្វើនេសាទអនាធិបតេយ្យឡើយ។ ប៉ុន្តែទោះជាខិតខំយ៉ាងណាក៏ដោយ ជាមួយដែននេសាទដ៏ធំធេងនោះ ក៏មិនទាន់អាចទប់ស្កាត់នូវបទល្មើសនេសាទបាន១០០%នៅឡើយ។ រីឯលទ្ធផលជាក់ស្តែងគឺបង្ក្រាបបទល្មើសបានចំនួន៣.៨០២ករណី ប្រៀបធៀបឆ្នាំមុនថយចុះចំនួន១.៥០៥ករណី ក្នុងនោះបានបំផ្លាញចោលវត្ថុតាងចំនួន៣.៤៨១ករណី ពិន័យអន្តរការណ៍ចំនួន២២៥ករណី បញ្ជូនទៅតុលាការចំនួន៩៦ករណី ដាក់ពន្ធនាគារចំនួន៥១នាក់ ប្រាក់ពិន័យនិងលក់វត្ថុតាងចំនួន១៥៧.៣៨០.០០០រៀល។ វត្ថុតាងដែលបានធ្វើការរុះរើបំផ្លាញចោលនិងដកហូតឃាត់ទុកបណ្តោះអាសន្នរួមមាន៖ របាំងស្បៃមុងនិងសាច់អួនប្រវែង១.០១០.៧៦៥ម៉ែត្រ របាំងព្រួលប្រវែង៩.៣៦០ម៉ែត្រ មងប្រវែង៣៤៧.២៧០ម៉ែត្រ ឈ្នក់/ឆ្នុកចំនួន២៧០គ្រឿង បរ/លូស្បៃមុងនិងសាច់អួនចំនួន១៥.៦៦៦មាត់ ឧបករណ៍ឆក់ត្រីចំនួន១.២៤១គ្រឿង អួនហ៊ុមចំនួន១១៩វង់ លប/តុម/ឡើ/បូម/សៃយឹនចំនួន២.១២៧គ្រឿង សន្ទូចចំនួន២៤.២៥០ផ្លែ ដាយត្រីចំនួន១៣៧មាត់ សំណាញ់/រ៉ៃហ៊ា/ជនចំនួន៨៥វង់ ម៉ាញ់/នាមចំនួន៣៦វង់ បង្គោល/ចម្រឹងចំនួន៤២២.២៥៩ដើម សម្រាស់ទំហំ៥៥.០៣៧ម៉ែត្រក្រឡា កាណូត/ទូកបំពាក់ម៉ាស៊ីនចំនួន១២០គ្រឿង ទូកចំនួន៥៥គ្រឿង លែងកូនត្រីប្រាម៉ឡប្រមាណ២.៧០០.០០០ក្បាល លែងកូនត្រីឆ្ពោននិងត្រីរស់ប្រមាណ៣៩៥.៦១៧ក្បាល លែងត្រីចម្រុះចូលដែនទឹកធម្មជាតិវិញចំនួន៩២.៦២៤គ.ក្រ អួនអូសចំនួន២៨ចូរ ផ្ទុងជាងចំនួន៤មាត់ ឈ្នាងអូសចំនួន២១គ្រឿង លែងកូនក្តាមប្រមាណ១.១២០កូន និងលែងកូនគ្រុំ/គ្រែងឈាមចំនួន៧៣៥គ.ក្រ។

បានប្រជុំផ្សព្វផ្សាយច្បាប់ លិខិតបទដ្ឋានគតិយុត្ត នៅតាមមូលដ្ឋានចំនួន ២៩៨វគ្គ អ្នកពាក់ព័ន្ធចូលរួមចំនួន២៥.២៥៩នាក់ ក្នុងនោះស្ត្រីចំនួន១០.៩៦០នាក់។

## ៩. ការសិក្សាស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវលើប្រភពធនធានជលផលទាំងទឹកសាបនិងសមុទ្របានដំណើរការល្អ ដោយមានកិច្ចសហប្រតិបត្តិការយ៉ាងជិតស្និទ្ធជាមួយដៃគូអភិវឌ្ឍនានាដូចជា JICA, MRC, FAO, EU, AIDA, World Fish Center ។ល។ ដោយមានវិទ្យាស្ថានស្រាវជ្រាវនិងអភិវឌ្ឍនេសាទទឹកសាប និងសមុទ្រជាអង្គភាពអនុវត្តផ្ទាល់។ ចំពោះលទ្ធផលស្រាវជ្រាវ ត្រូវបានបោះពុម្ពសៀវភៅផ្សព្វផ្សាយជាច្រើនពាន់ក្បាល និងប៉ុស្ទ័រជាច្រើនម៉ឺនសន្លឹក។

១០. ការរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យជលផល

ក្របខណ្ឌផែនការយុទ្ធសាស្ត្រសម្រាប់វិស័យជលផល១០ឆ្នាំ(២០១០-២០១៩) បានរៀបចំឡើងដោយសហការជាមួយដៃគូអភិវឌ្ឍន៍ក្នុងក្រុមការងារបច្ចេកទេសចម្រុះស្តីពីកំណែទម្រង់ជលផលតាំងពីឆ្នាំ២០០៨មកនោះ ត្រូវបានក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទអនុម័តឲ្យប្រើប្រាស់ជាផ្លូវការកាលពីថ្ងៃទី២១ ខែមីនា ឆ្នាំ២០១១រួចហើយ។ ខ្លឹមសារសំខាន់នៃផែនការយុទ្ធសាស្ត្រនេះ គឺជំរុញការផលិតត្រីឲ្យបាន១,២លានតោននៅឆ្នាំ២០១៩ ដើម្បីធានាតម្រូវការរបស់ប្រជាជន និងទីផ្សារនាំចេញ។

## ៦ ផ្នែករដ្ឋបាលនិងបុគ្គលិក

-ទទួលលិខិតពីក្រសួងនិងស្ថាប័ននានាសរុបចំនួន៥.៣១៧ច្បាប់ ទទួលពីអង្គភាពក្រោមឱវាទសរុបចំនួន៤.១៦៩ច្បាប់ និងទទួលពីរាជធានី ខេត្តសរុបចំនួន១.១៧៨ច្បាប់

-បញ្ជូនឯកសារនិងលិខិតទៅស្ថាប័នផ្សេងៗ អង្គភាពក្រោមឱវាទ និងរាជធានី ខេត្តសរុបចំនួន៨.៣៣៩ច្បាប់ ប្រកាស សេចក្តីសម្រេច និងសារាចរសរុបចំនួន៥៦១ច្បាប់ និងចម្លងចែកទៅអង្គភាពក្រោមឱវាទសរុបចំនួន៧៣៥ច្បាប់

-ក្រៅពីនេះគឺមានការទទួលរៀបចំកិច្ចប្រជុំផ្ទៃក្នុងរបស់ក្រសួង ការទទួលភ្ញៀវជាតិ អន្តរជាតិ ការចូលរួមរៀបចំពិធីបុណ្យជាតិ អន្តរជាតិ ការពង្រឹងផ្នែកសន្តិសុខ ...។ល។

-សូមបញ្ជាក់ថាមន្ត្រីរាជការ បុគ្គលិកនៅក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទមានចំនួនសរុបទាំងអស់ ៦.៦៦៤នាក់ (នារី១.២០៩នាក់) ក្នុងនោះថ្នាក់កណ្តាល៤.០៧៥នាក់ (នារី៦៨៨នាក់) ថ្នាក់ខេត្ត២.៥៨៩នាក់ (នារី៥២១នាក់)។ ក្នុងឆ្នាំ២០១៣នេះមានមន្ត្រីចូលនិវត្តន៍ចំនួន២១៧នាក់ ទទួលមរណភាពនិងលុបឈ្មោះ៤០នាក់និងបានជ្រើសរើសមន្ត្រីរាជការក្របខ័ណ្ឌថ្មីចំនួន១៦៨នាក់។

## ៧ ផ្នែកនីតិកម្មកសិកម្ម

### ៧.១ ការងារអាជីវកម្មសម្ភារកសិកម្ម

-ផ្តល់លិខិតអនុញ្ញាតធ្វើអាជីវកម្មសម្ភារកសិកម្មបានចំនួន១២ក្រុមហ៊ុន

-ផ្តល់វិញ្ញាបនបត្របញ្ជាក់បញ្ជិកាសម្ភារកសិកម្មនិងកម្រៃសេវាសាធារណៈបានចំនួន៣៤៧ក្រុមហ៊ុន

-ផ្តល់លិខិតអនុញ្ញាតនាំចេញ នាំចូលសម្ភារកសិកម្ម ក្នុងនោះថ្នាំកសិកម្មចំនួន៥១១មុខ ស្មើនឹង១៤.៨៩៧,២៤តោន និង៤០.០០០លីត្រ ជីកសិកម្មចំនួន៤២៨មុខ ស្មើនឹង៨៦៥.៤១៧,៩២តោន ចំណីសត្វចំនួន៤៤៣មុខ ស្មើនឹង១៦៣.៤៥៧,៨០តោន(នាំចេញចំនួន០៣មុខ ស្មើនឹង១០.០០០តោន) បសុឱសថចំនួន៤៧៦មុខ ស្មើនឹង២.១០៧,៧៤តោន គ្រាប់ពូជដំណាំចំនួន២៣មុខ ស្មើនឹង២.១០០តោន វត្ថុធាតុដើមចំនួន៣៨៣មុខ ស្មើនឹង២០៦.៦០៨,៤៥តោន និងបរិក្ខារចំនួន១៧៦មុខ។

### ៧.២ ការងារមន្ទីរពិសោធន៍

-ទទួលវិភាគលើសំណាកជីកសិកម្មបានចំនួន៨០ក្រុមហ៊ុន សរុបចំនួន៣៨៧សំណាក

-ចុះបញ្ជិកាថ្នាំកសិកម្មចំនួន២៨ក្រុមហ៊ុន ស្មើនឹង៥៥២មុខ ជីកសិកម្មចំនួន៨៦ក្រុមហ៊ុន ស្មើនឹង៤២២មុខចំណីសត្វចំនួន១៣ក្រុមហ៊ុន ស្មើនឹង២១៦មុខ បញ្ជិកាបសុឱសថចំនួន០៣ក្រុមហ៊ុន ស្មើនឹង១៨៦មុខ និងបញ្ជិកាគ្រាប់ពូជដំណាំ-បំណែកពូជដំណាំចំនួន០២ក្រុមហ៊ុន ស្មើនឹង១៣មុខ

-ចុះបញ្ជីឃ្លាំងសន្និធិ(ថ្នាំកសិកម្មនិងជីកសិកម្ម)ចំនួន១៧ក្រុមហ៊ុន ចែកចាយថ្នាំកសិកម្មនិងជីកសិកម្មចំនួន១៦ក្រុមហ៊ុន និងប្រតិបត្តិការលាយផ្សំឬវេចខ្ចប់ជាថ្មីនូវថ្នាំកសិកម្មនិងជីកសិកម្មចំនួន០១ក្រុមហ៊ុន។

### ៧.៣ ការងារផ្សព្វផ្សាយ

-ធ្វើសិក្ខាសាលាផ្សព្វផ្សាយស្តីពីបទដ្ឋានគតិយុត្ត នីតិវិធី និងបទដ្ឋានបច្ចេកទេសក្នុងការគ្រប់គ្រងសម្ភារកសិកម្ម (P3 P4)ចំនួន១៦ខេត្ត ដែលមានសិក្ខាកាមចូលរួមសរុបចំនួន៧៩៦នាក់

-អប់រំអាជីវករលក់ដុំ លក់រាយបានចំនួន០៨វគ្គ នៅខេត្តចំនួន០៧ ដែលមានអ្នកចូលរួមសរុបចំនួន៧៤៨នាក់។

### ៧.៤ ការងារវិវាទកសិកម្មនិងស្រាវជ្រាវ

-ចុះត្រួតពិនិត្យការនាំចូលសម្ភារកសិកម្មចំនួន៧២ក្រុមហ៊ុន

-ចុះត្រួតពិនិត្យមូលដ្ឋានអាជីវកម្មសម្ភារកសិកម្មចំនួន១២ខេត្ត សរុបចំនួន២៨៣ករណី និងចាត់វិធានការច្បាប់ចំនួន២៨៣ដេប៉ូ កែតម្រូវផ្ទាល់មាត់ចំនួន១០៨ករណី ពិនិត្យកែតម្រូវចំនួន១៤០ករណី ពិន័យអន្តរការណ៍ចំនួន០១ករណី ព្រមានចំនួន៦៩ករណី បញ្ឈប់ជាបណ្តោះអាសន្នចំនួន០១ករណី និងកសាងសំណុំរឿងបញ្ជូនទៅតុលាការចំនួន២៦ករណី។

## ៨ ផ្នែកសហប្រតិបត្តិការអន្តរជាតិ

-ក្រសួងបានខិតខំពង្រឹងកិច្ចសហប្រតិបត្តិការជាមួយអង្គការជាតិនិងអន្តរជាតិ កសាងគម្រោងនិងផែនការសកម្មភាពនានាស្វែងរកជំនួយនិងការគាំទ្រពីបណ្តាប្រទេសនិងដៃគូផ្តល់ជំនួយក្នុងការអភិវឌ្ឍវិស័យកសិកម្ម ដើម្បីចូលរួមការអនុវត្តគោលនយោបាយកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ ការរៀបចំប្រជុំក្នុងប្រទេសក្នុងក្របខណ្ឌនៃកិច្ចសហប្រតិបត្តិការផ្សេងៗ ការត្រៀមរៀបចំកិច្ចប្រជុំលើកទី៣៥ នៃរដ្ឋមន្ត្រីកសិកម្មនិងព្រៃឈើអាស៊ាន ព្រមទាំងកិច្ចប្រជុំអមមួយចំនួនទៀត និងធ្វើជាម្ចាស់ផ្ទះសម្រាប់កិច្ចប្រជុំស្តីពីវិស័យកសិកម្មនិងព្រៃឈើអាស៊ានឆ្នាំ២០១៤ ធ្វើជាម្ចាស់ផ្ទះរៀបចំកិច្ចប្រជុំលើកទី១០ ស្តីពីបណ្តាញត្រួតពិនិត្យអាស៊ានលើចំណីអាហារដែលមានប្រភពពីផលិតផលបម្រែបម្រួលហ្សែន និងត្រៀមចូលរួមកិច្ចប្រជុំកំពូល ACMECS លើកទី៥ និងCLMV លើកទី៦

-ក្នុងឆ្នាំ២០១៣នេះថ្នាក់ដឹកនាំក្រសួង និងមន្ត្រីរាជការក្រោមឱវាទបានទៅចូលរួមប្រជុំ សន្និសីទ សិក្ខាសាលា វគ្គបណ្តុះបណ្តាល និងទស្សនកិច្ចសិក្សាបានចំនួន៤៤៥នាក់ នៅក្នុងប្រទេសចំនួន៣០។ ក្រៅពីនេះក៏បានទទួលរៀបចំកិច្ចព្រមព្រៀង (MoU) ជាមួយអង្គការជាតិ-អន្តរជាតិនិងប្រទេសផ្តល់ជំនួយនានាដើម្បីចូលរួមអភិវឌ្ឍវិស័យកសិកម្មនៅកម្ពុជា ក៏ដូចជាការសម្របសម្រួលកិច្ចសន្ទនាការការទូតនិងកិច្ចសហប្រតិបត្តិការតាមផ្នែកនីមួយៗយ៉ាងសកម្ម។ ទន្ទឹមនឹងនេះ ក៏មិនភ្លេចផងដែរនូវអំណរគុណដ៏ជ្រាលជ្រៅចំពោះបណ្តាប្រទេសជាមិត្តអង្គការជាតិ-អន្តរជាតិដែលបានរួមចំណែកយ៉ាងសកម្មក្នុងការជួយសង្គ្រោះបន្ទាន់ដល់ប្រជាពលរដ្ឋដែលរងគ្រោះដោយទឹកជំនន់ក្នុងឆ្នាំ២០១៣ កន្លងមកនេះ។

## ៩ ផ្នែកវិទ្យាស្ថានស្រាវជ្រាវនិងអភិវឌ្ឍន៍កសិកម្មកម្ពុជា

-ចូលរួមប្រជុំនិងសិក្ខាសាលាផ្សេងៗចំនួន២០លើកនៅប្រទេសអូស្ត្រាលី អ៊ីតាលី ជប៉ុន ម៉ាឡេស៊ី ចិន ហ្វីលីពីន កូរ៉េ ឥណ្ឌូនេស៊ី ឡាវ ឥណ្ឌា អូមែន ស្រីលង្កា និងថៃ

-ប្រារព្ធទិវាស្បៀងអាហារពិភពលោកឆ្នាំ២០១៣ ដោយសហការជាមួយអង្គការ WFP FAO ដែលមានអ្នកចូលរួមចំនួន៦០០នាក់

-ធ្វើបទបង្ហាញអំពីលទ្ធផលការងារពិសោធន៍ស្រាវជ្រាវនិងពិភាក្សា ព្រមទាំងផ្តល់ប្រឹក្សាចំនួន៤៧លើក ជាមួយគណៈប្រតិភូ ភ្ញៀវជាតិ និងអន្តរជាតិចំនួន១៦៦នាក់

-ធ្វើពិសោធន៍ចំនួន៧៤ប្រភេទ នៅលើទីតាំង៥៧៥កន្លែង ក្នុងនោះពិសោធន៍បន្សាំពូជលើស្រែកសិករនិងស្រែបង្ហាញចំនួន៣៧៧កន្លែង

-ធ្វើអង្កេតចំនួន១០ប្រភេទដោយធ្វើសម្ភាសន៍កសិករចំនួន៥.០០០គ្រួសារ

-រៀបចំនិងបោះពុម្ពសៀវភៅស្ដោចម្រៃនៃដំណាំស្រូវនៅអាស៊ី ព្រឹត្តិបត្រព័ត៌មានកសិករអំពីខ្យងពណ៌មាស និងវិធានការកម្ចាត់ និងរបាយការណ៍ប្រចាំឆ្នាំចំនួន២២.៥០០ច្បាប់ ព្រមទាំងបានធ្វើការបែងចែកសៀវភៅឯកសារបច្ចេកទេសនានាចំនួន៣.៦០០ច្បាប់ និងព្រឹត្តិបត្រព័ត៌មានកសិករចំនួន១៤.៧០០ច្បាប់

-ធ្វើយុវកម្មលើដំណាំចំនួន២ប្រភេទ រួមមានដំណាំស្រូវចំនួន៦៩០បញ្ជីក/សំណាក(ដុះបាន៥៣៣បញ្ជីក/សំណាក) ដំណាំអំពៅចំនួន២៧សំណាក និងបានចុះប្រមូលពូជស្រូវប្រពៃណីពីខេត្តកោះកុងចំនួន៤១សំណាក និងស្វាយចំនួន២៤សំណាកពីបណ្តាខេត្តនានា

-បន្តអភិរក្សលើដំណាំចំនួន៣០ប្រភេទ ក្នុងនោះស្រូវចំនួន៥.៩៦០បញ្ជីក/សំណាក និងដំណាំផ្សេងៗទៀតចំនួន២៩ប្រភេទរួមមាន៩៦៥សំណាក សរុបទាំងអស់ចំនួន៦.៩២៥បញ្ជីក/សំណាក

-ធ្វើទិវាស្រែបង្ហាញចំនួន១០កន្លែង ដែលមានកសិករចូលរួមសរុប២៥០នាក់ និងបានចែកពូជស្រូវផ្ការំដួលនិងផ្ការមៀតតាមគោលនយោបាយជំរុញផលិតកម្មស្រូវនិងការនាំអង្ករចេញជូនដល់កសិករចំនួន១៦៦គ្រួសារ (ក្នុងមួយគ្រួសារចំនួន៥គីឡូក្រាម) នៅខេត្តស្ទឹងត្រែង ខេត្តមណ្ឌលគិរី និងខេត្តព្រះវិហារ

-បើកវគ្គបណ្តុះបណ្តាល សិក្ខាសាលា និងសន្និបាតចំនួន១០វគ្គ ដែលមានអ្នកចូលរួមសរុបចំនួន២២៥នាក់

-ចូលរួមវគ្គបណ្តុះបណ្តាល សិក្ខាសាលា និងសន្និបាតក្នុងប្រទេសចំនួន១៤លើក ដែលមានអ្នកចូលរួមចំនួន២៣នាក់ និងក្រៅប្រទេសចំនួន៣៥លើក ដែលមានអ្នកចូលរួមចំនួន៤៩នាក់

-ការស្រាវជ្រាវរកព័ត៌មានបច្ចេកទេសកសិកម្មក្នុងគេហទំព័រ www.cardi.org.kh និង www.crkb.org.kh មានអ្នកចូលរួមសរុបចំនួន៣២២.៩០០នាក់ គិតជាមធ្យមប្រមាណ៨៩៦នាក់ក្នុងមួយថ្ងៃ សរុបចំនួន៩៩ប្រទេស។

## ១០ សាលាជាតិកសិកម្មព្រែកលៀប

### ១០.១ និស្សិតដែលកំពុងសិក្សានាឆ្នាំសិក្សា២០១៣-២០១៤ សរុបមានចំនួន១.៥៦២នាក់ (ស្រី៥០២នាក់)ក្នុងនោះ៖

- និស្សិតអាហារូបករណ៍(ទូទៅ)ចំនួន១.០៥០នាក់ ក្នុងនោះស្រី៣៩៣នាក់ ៖

-ថ្នាក់បរិញ្ញា៨១៣នាក់ (ស្រី៣០៥នាក់) សិក្សាលើមុខជំនាញវិទ្យាសាស្ត្រកសិកម្ម វិទ្យាសាស្ត្រព្រៃឈើ វិទ្យាសាស្ត្រនិងវេជ្ជសាស្ត្រសត្វ វិទ្យាសាស្ត្រជលផល ផ្សព្វផ្សាយនិងអភិវឌ្ឍន៍ជនបទ សាកវប្បកម្ម សេដ្ឋកិច្ចនិងគ្រប់គ្រងកសិកម្ម កសិឧស្សាហកម្ម និងសុរិយោដី

-ថ្នាក់បរិញ្ញារង២៣៧នាក់ (ស្រី៨៨នាក់) សិក្សាលើមុខជំនាញក្សេត្រសាស្ត្រ រុក្ខកម្ម ផលិតកម្មនិងបសុព្យាបាល ផ្សព្វផ្សាយនិងអភិវឌ្ឍន៍ជនបទ សាកវប្បកម្ម សេដ្ឋកិច្ចនិងគ្រប់គ្រងកសិកម្ម ជលផល កសិឧស្សាហកម្ម និងសុរិយោដី។

- និស្សិតបង់ថ្លៃចំនួន១៩៦នាក់ ក្នុងនោះស្រី២៧នាក់ ៖

-ថ្នាក់បរិញ្ញា១៥៤នាក់ (ស្រី២៤នាក់ )សិក្សាលើមុខជំនាញវិទ្យាសាស្ត្រកសិកម្ម វិទ្យាសាស្ត្រព្រៃឈើ វិទ្យាសាស្ត្រនិងវេជ្ជសាស្ត្រសត្វ វិទ្យាសាស្ត្រជលផល ផ្សព្វផ្សាយនិងអភិវឌ្ឍន៍ជនបទ សេដ្ឋកិច្ចកសិកម្ម កសិឧស្សាហកម្ម និងសុរិយោដី

-ថ្នាក់បរិញ្ញារង៤២នាក់ (ស្រី០៣នាក់) សិក្សាលើមុខជំនាញក្សេត្រសាស្ត្រ រុក្ខកម្ម ផលិតកម្មនិងបសុព្យាបាល និងផ្សព្វផ្សាយនិងអភិវឌ្ឍន៍ជនបទ។

- និស្សិតបណ្តុះបណ្តាលបន្តថ្ងៃសៅរ៍-អាទិត្យចំនួន១៦១នាក់ ក្នុងនោះ ស្រី៣៧នាក់ ៖

-ថ្នាក់បរិញ្ញា១៤២នាក់ (ស្រី៣៦នាក់) សិក្សាលើមុខជំនាញវិទ្យាសាស្ត្រកសិកម្ម វិទ្យាសាស្ត្រនិងវេជ្ជសាស្ត្រសត្វ និងសុរិយោដី

-ថ្នាក់បរិញ្ញារង១៩នាក់ (ស្រី០១នាក់) សិក្សាលើមុខជំនាញផលិតកម្មនិងបសុព្យាបាល ។

### ១០.២ ការងារផលិតកម្មនិងស្រាវជ្រាវ

-កសិដ្ឋានដំណាំលម្អបានដាំផ្កា ឈើពណ៌ ដូងតាំង និងពង្រីកពូជបន្ថែមសម្រាប់ការអនុវត្តនិងដាំលម្អក្នុងបរិវេណសាលាជាតិ បណ្តុះកូនក្ងាន ស្លាកន្ទុយកំប្រុក។

## ១១ សាលាជាតិកសិកម្មកំពង់ចាម

### ១១.១ និស្សិតដែលកំពុងសិក្សានាឆ្នាំសិក្សា២០១២-២០១៣ សរុបមានចំនួន១.៥៥៩នាក់(ស្រី៦០៨នាក់)ក្នុងនោះ ៖

-និស្សិតអាហារូបករណ៍សរុប១.២៩៥នាក់(ស្រី៥៣៥នាក់)ក្នុងនោះថ្នាក់បរិញ្ញាវិទ្យាសាស្ត្រកសិកម្ម៩១៣នាក់ (ស្រី៣៣៩នាក់) និងថ្នាក់បរិញ្ញារងបច្ចេកទេសកសិកម្ម៣៨២នាក់(ស្រី១៩៦នាក់) ដែលកំពុងសិក្សាមុខជំនាញក្សេត្រសាស្ត្រ វិទ្យាសាស្ត្រនិងវេជ្ជសាស្ត្រសត្វ វិទ្យាសាស្ត្រជលផល ដំណាំកៅស៊ូ សេដ្ឋកិច្ចកសិកម្មនិងអភិវឌ្ឍន៍ជនបទ

-និស្សិតសិក្សាបង់ថ្លៃ២៦៤នាក់ (ស្រី៧៣នាក់) ថ្នាក់បរិញ្ញាចំនួន២៥២នាក់(ស្រី៧៣នាក់) និងថ្នាក់បរិញ្ញារងចំនួន១២នាក់(ស្រី០នាក់) កំពុងសិក្សាមុខជំនាញក្សេត្រសាស្ត្រ វិទ្យាសាស្ត្រនិងវេជ្ជសាស្ត្រសត្វ វិទ្យាសាស្ត្រជលផល ដំណាំកៅស៊ូ និងសេដ្ឋកិច្ចកសិកម្មនិងអភិវឌ្ឍន៍ជនបទ ។

### ១១.២ ការងារពិសោធន៍ស្រាវជ្រាវ

-ធ្វើការពិសោធន៍ដំណាំសណ្តែកសៀង

-ធ្វើការពិសោធន៍លើប្រសិទ្ធភាពជីអាសូត ផូស្វរ ប៉ូតាស្យូម លើការលូតលាស់ដំណាំម្ទេសដៃនាង

-ពិសោធន៍តាមដានការលូតលាស់ជ្រូកមេក្នុងការចិញ្ចឹមតាមរយៈការប្រើប្រាស់ចំណីឧស្សាហកម្ម។

### ១១.៣ ការងារស្រាវជ្រាវ ផ្សព្វផ្សាយ និងការផ្ទេរបច្ចេកវិទ្យាកសិកម្ម

-លើកគម្រោងចំនួន១១ស្នើសុំថវិកាសម្រាប់ធ្វើការស្រាវជ្រាវលើប្រធានបទស្តីពីការពិសោធន៍កសិកម្ម វារីវប្បកម្ម

បសុវប្បកម្ម និងសង្គមជនបទ

-បន្តការងារស្រាវជ្រាវផលិតកម្មដំណាំស្រូវ ដែលបានឧបត្ថម្ភជំនួយពី ACIAR-CARF

-បន្តការងារស្រាវជ្រាវលើបសុវប្បកម្ម ដែលបានឧបត្ថម្ភជំនួយពី DEL-phe(UK)

-ផ្សព្វផ្សាយពីការធ្វើឥណទានស្រូវពូជ ជ្រូកពូជ និងចាក់វ៉ាក់សាំងការពារជំងឺសត្វគោ-ក្របី នៅតាមមូលដ្ឋានឃុំ-ស្រុក ក្នុងខេត្តកំពង់ចាម

-ផ្តល់ជ្រូកពូជជូនដល់កសិករក្រីក្រនៅស្រុកត្រាំកក់ខេត្តតាកែវនិងស្រុកស្ទឹងត្រង់ ខេត្តកំពង់ចាមបានចំនួន១៨គ្រួសារ

-ធ្វើការប្រជុំកសិករណែនាំពីការប្រើប្រាស់ថ្នាំកសិកម្ម ជីគីមី និងជីសរីរាង្គ នៅក្នុងមូលដ្ឋានស្រុកត្រាំកក់ ខេត្តតាកែវ និងស្រុកស្ទឹងត្រង់ ខេត្តកំពង់ចាម។

## ១២ សាកលវិទ្យាល័យភូមិន្ទកសិកម្ម

-និស្សិតដែលកំពុងសិក្សាមានចំនួនសរុប៥.៦៩៧នាក់ (ស្រី១.២៣៣នាក់) ចែកចេញជា០៩មហាវិទ្យាល័យគឺ មហាវិទ្យាល័យវិទ្យាសាស្ត្រកសិកម្ម វិទ្យាសាស្ត្រនិងវេជ្ជសាស្ត្រសត្វ វិទ្យាសាស្ត្រព្រៃឈើ វិទ្យាសាស្ត្រជលផល វិស្វកម្មកសិកម្ម សេដ្ឋកិច្ចកសិកម្មនិងអភិវឌ្ឍន៍ជនបទ កសិឧស្សាហកម្ម រៀបចំដែនដីនិងរដ្ឋបាលដីធ្លី វិទ្យាសាស្ត្រកៅស៊ូ ដែលសិក្សាតាមកម្មវិធីថ្នាក់បរិញ្ញាវិទ្យាសាស្ត្រនិងសាលាក្រោយឧត្តម បណ្តុះបណ្តាលលើកម្មវិធីបរិញ្ញារង បរិញ្ញាបត្រ បរិញ្ញាជាន់ខ្ពស់ និងថ្នាក់បណ្ឌិតវិទ្យាសាស្ត្រ

-បើកវគ្គបណ្តុះបណ្តាលក្នុងប្រទេសចំនួន២៥លើក និងចូលរួមនៅក្រៅប្រទេសចំនួន២១លើក និងសិក្ខាសាលាក្នុងប្រទេសចំនួន២៤លើក និងក្រៅប្រទេសចំនួន២២លើក

-បញ្ជូននិស្សិតទៅចូលរួមវគ្គបណ្តុះបណ្តាលនិងកម្មសិក្សានៅក្រៅប្រទេសចំនួន១២នាក់ និងមន្ត្រីរាជការចំនួន១២នាក់

-បញ្ជូននិស្សិតទៅធ្វើកម្មសិក្សានៅប្រទេសអ៊ីស្រាអែលចំនួន៣០នាក់

-អនុវត្តគម្រោងស្រាវជ្រាវនិងអភិវឌ្ឍន៍ចំនួន២៣គម្រោង គម្រោងទាំងនោះមានគម្រោងស្រាវជ្រាវនិងអភិវឌ្ឍន៍ចម្រុះជំនាញផ្នែកវិទ្យាសាស្ត្រកសិកម្ម ផ្នែកវិទ្យាសាស្ត្រនិងវេជ្ជសាស្ត្រសត្វ ផ្នែកវិទ្យាសាស្ត្រព្រៃឈើ ផ្នែកវិទ្យាសាស្ត្រជលផល ផ្នែកស្រាវជ្រាវ-ផ្សព្វផ្សាយ ផ្នែករៀបចំដែនដីនិងរដ្ឋបាលដីធ្លី

-ធ្វើការផ្លាស់ប្តូរបទពិសោធន៍ពីគ្នាទៅវិញទៅមករវាងសាស្ត្រាចារ្យនិងនិស្សិត ព្រមទាំងខិតខំពង្រឹងកិច្ចសហប្រតិបត្តិការអន្តរជាតិយ៉ាងទូលំទូលាយ ក្នុងទិសដៅពង្រឹងគុណភាពអប់រំឱ្យបានល្អប្រសើរដើម្បីឱ្យមានលក្ខណៈប្រកួតប្រជែង

-បញ្ជូននិស្សិតចុះជួយវាស់វែងដីធ្លីជូនប្រជាជន ដើម្បីចូលរួមអនុវត្តគោលនយោបាយចាស់សកម្មភាពថ្មីលើវិស័យដីធ្លីរបស់រាជរដ្ឋាភិបាលចំនួន៤២៩នាក់ មកពីមហាវិទ្យាល័យរៀបចំដែនដីនិងរដ្ឋបាលដីធ្លី វិទ្យាសាស្ត្រកសិកម្ម និងសេដ្ឋកិច្ចកសិកម្មនិងជនបទ។

## III-ផែនការ គោលនយោបាយសម្រាប់អភិវឌ្ឍកសិកម្ម ២០១៤-២០១៨

យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ត្រូវបានដាក់ចេញឱ្យអនុវត្តក្នុងអាណត្តិទី៥។ មុំទី១នៃយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣(២០១៤-២០១៨)គឺបានសង្កត់ធ្ងន់ការលើកស្ទួយវិស័យកសិកម្ម ដែលមានគោលនយោបាយចំនួន៤រួមមាន៖

- ការលើកកម្ពស់ផលិតភាព ពិពិធភាវូបនីយកម្មកសិកម្ម និងពាណិជ្ជូបនីយកម្មកសិកម្ម
- ការលើកកម្ពស់ការចិញ្ចឹមសត្វ
- កំណែទម្រង់ដីធ្លី ការបោសសម្អាតមីន និងសំណល់ជាតិផ្ទុះពីសង្គ្រាម
- ការគ្រប់គ្រងធនធានធម្មជាតិប្រកបដោយចីរភាព

ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ២០១៤-២០១៨ នឹងត្រូវរៀបចំឱ្យស្របទៅនឹងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ២០១៤-២០១៨ ដែលនឹងដាក់ចេញនាពេលខាងមុខ។ ការកំណត់ទិសដៅគោលនយោបាយរួមរបស់ក្រសួងសម្រាប់អនុវត្តរយៈពេល៥ឆ្នាំគឺ៖

ទិសដៅគោលនយោបាយរួម (Overall Policy Goal) ៖ "ជំរុញកំណើនកសិកម្មក្នុងរង្វង់៤-៥%ក្នុងមួយឆ្នាំតាមរយៈការលើកកម្ពស់ផលិតភាព ពិពិធភាវូបនីយកម្ម និងពាណិជ្ជូបនីយកម្មកសិកម្ម ដោយយកចិត្តទុកដាក់ខ្ពស់លើការការពារនិងគ្រប់គ្រងធនធានព្រៃឈើនិងជលផលប្រកបដោយចីរភាព"។

ផ្អែកលើទិសដៅគោលនយោបាយរួមរបស់ក្រសួងដែលបានកំណត់នេះ ទិសដៅគោលនយោបាយលម្អិតតាមផ្នែកត្រូវបានឯកភាពកំណត់ដូចខាងក្រោម៖

ទិសដៅគោលនយោបាយតាមផ្នែក(03 Specific Policy Goals) ៖

ទី-1 "ការបង្កើនផលិតភាព ពិពិធភាវូបនីយកម្មកសិកម្ម និងពាណិជ្ជូបនីយកម្មកសិកម្ម"

ទី-2 "ការលើកកម្ពស់ការចិញ្ចឹមសត្វ"

ទី-3 "ការគ្រប់គ្រងធនធានព្រៃឈើនិងជលផលប្រកបដោយចីរភាព"

ដើម្បីសម្រេចទិសទិសដៅគោលនយោបាយតាមផ្នែកទាំង៣នេះ ក្រសួងនឹងមានកម្មវិធីថ្មីចំនួន៥ (២០១៤-២០១៨) ដូចខាងក្រោមនេះ៖

**កម្មវិធីទី-១៖ បង្កើនផលិតភាព ពិពិធកម្មកសិកម្មនិងពាណិជ្ជូបនីយកម្មកសិកម្ម**

"ជំរុញកំណើនផលិតកម្មគ្រប់មុខដំណាំក្នុងរង្វង់១០%ក្នុងមួយឆ្នាំ តាមរយៈការបង្កើនការស្រាវជ្រាវ និងផ្សព្វផ្សាយកសិកម្មសំដៅបង្កើនទិន្នផលដំណាំ លើកកម្ពស់គុណភាពផលិតផល ពង្រឹងសមត្ថភាពសហគមន៍កសិកម្ម ដោយផ្សារភ្ជាប់ជាមួយផលិតកម្មកសិកម្មតាមកិច្ចសន្យា និងបង្កើនប្រសិទ្ធភាពនៃការគ្រប់គ្រង និងប្រើប្រាស់ដីប្រកបដោយនិរន្តរភាព"។

**កម្មវិធីទី-២៖ជំរុញផលិតកម្មសត្វនិងសុខភាពសត្វ**

"ជំរុញការចិញ្ចឹមសត្វក្នុងអត្រាកំណើន៣ភាគរយក្នុងមួយឆ្នាំ ដោយផ្អែកលើប្រសិទ្ធភាពនៃការពិសោធន៍ស្រាវជ្រាវនិងផ្សព្វផ្សាយ បង្កើនសមត្ថភាពបង្ការទប់ស្កាត់ជំងឺឆ្លងសត្វ និងជំងឺសូណូស៊ីស ធានាការផ្គត់ផ្គង់សត្វ សាច់សត្វប្រកបដោយអនាម័យ សុវត្ថិភាព និងបង្កើនសក្តានុភាពនៃការនាំចេញ"។

**កម្មវិធីទី-៣៖ ពង្រឹងស្ថាប័ន បង្កើនប្រសិទ្ធភាពសេវាគាំទ្រ និងអភិវឌ្ឍន៍ធនធានមនុស្ស**

"បង្កើនប្រសិទ្ធភាពនៃការគ្រប់គ្រងស្ថាប័ន ការផ្តល់សេវាគាំទ្រ និងពង្រឹងសមត្ថភាពផ្នែកអប់រំនិងបណ្តុះបណ្តាលសម្រាប់ការអភិវឌ្ឍវិស័យកសិកម្មប្រកបដោយនិរន្តរភាព"។

**កម្មវិធីទី-៤៖ ការគ្រប់គ្រងធនធានជលផលប្រកបដោយនិរន្តរភាព**

"បង្កើនការការពារធនធានជលផល បង្កើតតំបន់អភិរក្ស លុបបំបាត់បទល្មើសនេសាទគ្រប់រូបភាព ធានាឱ្យបាននូវផ្ទៃនេសាទសម្រាប់សហគមន៍នេសាទ និងបង្កើនផលិតកម្មនេសាទ លើមូលដ្ឋានជំរុញវារីវប្បកម្មក្នុងរង្វង់១៥%ក្នុងមួយឆ្នាំ និងពង្រឹងសមត្ថភាព១០០សហគមន៍នេសាទជារៀងរាល់ឆ្នាំ"។

**កម្មវិធីទី-៥៖ ការគ្រប់គ្រងធនធានព្រៃឈើនិងសត្វព្រៃប្រកបដោយនិរន្តរភាព**

"បង្កើនការគ្រប់គ្រងព្រៃឈើនិងសត្វព្រៃប្រកបដោយនិរន្តរភាព តាមរយៈការពង្រឹងការអនុវត្តច្បាប់ ជំរុញការដាំឈើឱ្យបានយ៉ាងតិច២៥.០០០ហ.តក្នុង១ឆ្នាំ បង្កើតព្រៃការពារនិងតំបន់អភិរក្សសត្វព្រៃឱ្យបាន៥០.០០០ហ.តក្នុង១ឆ្នាំ និងសហគមន៍ព្រៃឈើឱ្យបាន២៥សហគមន៍ក្នុង១ឆ្នាំយ៉ាងតិច"។

## IV-សេចក្តីសន្និដ្ឋាននិងវាយតម្លៃ

ផ្អែកលើលទ្ធផលទទួលបានក្នុងរយៈពេលពេញមួយឆ្នាំ២០១៣កន្លងមកនេះ យើងអាចវាយតម្លៃជារួមថា បើទោះបីជាបានជួបប្រទះនូវគ្រោះធម្មជាតិរួមមានកង្វះខាតទឹកដោយសារកូនរដូវប្រាំងនៅពាក់កណ្តាលរដូវវស្សា គ្រោះជំនន់ទឹកភ្លៀងរដូវវស្សា តែក្រោមការខិតខំប្រឹងប្រែងរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ តាមការណែនាំនិងតម្រង់ទិសក៏ដូចជាវិធានការឆ្លើយតបយ៉ាងមានប្រសិទ្ធភាពរបស់រាជរដ្ឋាភិបាលកម្ពុជា ដោយមានការចូលរួមដ៏សកម្មពីគ្រប់ក្រសួងស្ថាប័ន អាជ្ញាធរមូលដ្ឋាន កងកម្លាំងប្រដាប់អាវុធ មន្ទីរកសិកម្មរាជធានី-ខេត្ត និងប្រជាកសិករទូទាំងប្រទេស ព្រមទាំងការរួមចំណែកពីដៃគូអភិវឌ្ឍន៍ផងនោះ បានធ្វើឱ្យផលិតកម្មកសិកម្ម មានការរីកចម្រើនគួរឱ្យកត់សម្គាល់និងជាទីមោទនៈ។

ផលិតកម្មដំណាំពិសេសដំណាំស្រូវរយៈពេល៥ឆ្នាំ (២០០៩-២០១៣) នេះ បានទទួលលទ្ធផលគួរជាទីពេញចិត្ត ដែលជាលទ្ធផលគឺកម្ពុជាទទួលបានបរិមាណផលស្រូវចំនួន៩,៣៤លានតោន និងអាចសល់ស្បៀង (ជាអង្ករ) សរុបចំនួនជាង៣លានតោន (ឬ៤,៧៨លានតោនស្រូវ) នៅឆ្នាំ២០១៣ ដែលនេះជាជោគជ័យមួយគួរជាទីមោទនៈបំផុតសម្រាប់កម្ពុជា។ ផ្អែកលើសមិទ្ធផលខាងលើនេះ យើងអាចវាយតម្លៃជារួមបានថាផលិតកម្មកសិកម្មកម្ពុជាយើង ពិសេសផលិតកម្មស្រូវ ពីមួយឆ្នាំទៅមួយឆ្នាំ មានការវិវឌ្ឍឈានឡើងជាលំដាប់ ដោយសារកត្តា២យ៉ាងគឺ (១) ការពង្រីកដីដាំដុះ

ដែលរួមទាំងការធ្វើបង្កើនរដូវ ជាពិសេសនោះគឺ (២) កត្តាកើនឡើងនៃទិន្នផល ដែលជាសមិទ្ធផលនៃការសិក្សាស្រាវជ្រាវ ផ្សព្វផ្សាយពូជថ្មី បច្ចេកទេសដាំដុះ និងការថែទាំ។ ពិសេសការយល់ដឹងរបស់កសិករលើការផលិតពីគ្រប់ហូបចុកទៅការធ្វើកសិពាណិជ្ជកម្មវិញ។

ដំណាំរួមផ្សំនិងឧស្សាហកម្ម ដំណាំឈើហូបផ្លែនិងដំណាំអចិន្ត្រៃយ៍ កំពុងមានការរីកចម្រើនជាបន្តបន្ទាប់ ជាលក្ខណៈគ្រួសារនិងជាលក្ខណៈវិនិយោគខ្នាតតូច មធ្យម និងធំ ជាក់ស្តែង ផ្ទៃដីដាំដុះកៅស៊ូមានសន្ទុះកើនឡើង ពិសេសការអភិវឌ្ឍកៅស៊ូគ្រួសារ មានការវិវឌ្ឍន៍តាមសន្ទុះមួយគួរឱ្យចាប់អារម្មណ៍។

ផលិតកម្មសត្វ គោ ក្របី ជ្រូក មាន់ ទា មានការវិវឌ្ឍន៍រីកចម្រើនគួរឱ្យកត់សម្គាល់ ដោយសារការបង្កើនការងារផ្សព្វផ្សាយពូជ ការបង្ការជំងឺឆ្លងសត្វ និងការពង្រីកចំណេះដឹងផ្នែកបច្ចេកទេសនៃការចិញ្ចឹមសត្វ ដល់ប្រជាកសិករបានទូលាយជាងមុន។

ការគ្រប់គ្រងធនធានធម្មជាតិ ព្រៃឈើ និងជលផល កំពុងស្ថិតនៅតែជាប្រធានបទតឹងតែង ស្មុគស្មាញ ហើយដែលត្រូវតែខិតខំបន្តសកម្មភាព ជាមួយនឹងការបន្តពង្រឹងការអនុវត្តច្បាប់ និងបទដ្ឋានផ្សេងៗ។

លើសពីនេះទៅទៀត ផ្នែកសេវាកម្ម និងការគាំទ្រផ្សេងៗក៏បានសម្រេចនូវលទ្ធផលការងារតាមផ្នែកនីមួយៗបានល្អប្រសើរ ស្របតាមគោលការណ៍ និងទិសដៅរបស់រាជរដ្ឋាភិបាល។ ជារួមគ្រប់សកម្មភាពទាំងអស់តាមផ្នែកនីមួយៗក៏ដូចជាការអនុវត្តគម្រោងផ្សេងៗក៏ពុំដែលបំភ្លេច ឬមើលរំលងពីការបញ្ជូលអាទិភាពយេនឌ័រនៅក្នុងនោះឡើយ តែទោះជាយ៉ាងណាក្តី ផ្លូវនៅវែងឆ្ងាយទៀត ដើម្បីសម្រេចបានគោលដៅ និងមហិច្ឆតាធំធេងដែលយើងចង់បាន សម្រាប់ការអភិវឌ្ឍវិស័យកសិកម្មកម្ពុជាមួយតាមលក្ខណៈវិទ្យាសាស្ត្រទំនើប និងមានប្រសិទ្ធភាពខ្ពស់ ជាពិសេស ការចូលរួមកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ ការលើកកម្ពស់កំណើនសេដ្ឋកិច្ចជាតិ តាមទិសដៅអភិវឌ្ឍន៍សហសវត្សរ៍កម្ពុជាក៏ដូចជាក្នុងបរិបទនៃសកលភាវូបនីយកម្ម ក្រោមការដឹកនាំតម្រង់ទិសប្រកបដោយគតិបណ្ឌិត និងម៉ឺងម៉ាត់បំផុតរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា។

## V- ទិសដៅ

-បន្តតាមដានជំរុញការប្រមូលផលស្រូវរដូវវស្សាឲ្យបានល្អ និងវាយតម្លៃទិន្នផល និងបរិមាណផលទទួលបានឲ្យបានច្បាស់លាស់

-សហការជាមួយអាជ្ញាធរដែនដីធ្វើការអប់រំផ្សព្វផ្សាយដល់ប្រជាកសិករឲ្យយកចិត្តទុកដាក់ជំរុញការងារមុនប្រមូលផល និងក្រោយពេលប្រមូលផលស្រូវ ដោយត្រូវប្រមូលផ្តុំរក្សាទុកដាក់ក្នុងជម្រុកឱ្យបានល្អតាមបច្ចេកទេសដើម្បីធានាសន្តិសុខស្បៀងក្នុងគ្រួសារផង និងការលៃទុកពូជផង

-តាមដានជាប់ជាប្រចាំនូវដំណើរការបង្កបង្កើនផលស្រូវប្រាំង ដើម្បីណែនាំជំរុញការដាំដុះនៅតំបន់ដែលមានប្រភពទឹកស្រោចស្រពគ្រប់គ្រាន់ ដោយសហការជាមួយមន្ទីរធនធានទឹក និងអាជ្ញាធរមូលដ្ឋាន សម្របសម្រួលបែងចែកការប្រើប្រាស់ទឹកស្រោចស្រព និងអន្តរាគមន៍បូមបាចតាមស្ថានភាពជាក់ស្តែង និងចាំបាច់។ សម្រាប់ស្រូវរដូវប្រាំងត្រូវបន្តផ្សព្វផ្សាយឲ្យកសិករប្រើប្រាស់ពូជល្អមានទិន្នផលខ្ពស់ ជាពិសេសពូជ IR 66 ពូជផលសារ។ល។

-តាមដាននិងអន្តរាគមន៍ចំពោះការផ្ទុះរាលដាល និងការបំផ្លាញដោយសត្វល្អិតជាយថាហេតុ

-តាមដានចលនានាំចេញស្រូវនិងថ្លៃស្រូវ ជាពិសេសតាមច្រកព្រំដែននានា

-បន្តជំរុញអប់រំផ្សព្វផ្សាយឱ្យប្រជាកសិករដាំដំណាំផ្សេងទៀត ឬប្រើប្រាស់ពូជស្រូវសមស្របជាមួយនឹងការប្រើប្រាស់ទឹកដោយប្រសិទ្ធភាព ជាពិសេសចំពោះខេត្តដែលមានអតុល្យភាពស្បៀង (អង្គរ) ដោយ ជំរុញកសិករឲ្យឆ្លៀតឱកាសដាំដំណាំរួមផ្សំ ដូចជា ៖ ពោត ដំឡូង បន្លែ សណ្តែក លើតំបន់ដីដែលនៅមានសំណើមអាចដាំដុះបាន បន្ទាប់ពីប្រមូលផលស្រូវវស្សា ដើម្បីបានផលកម្រៃបន្ថែមដល់សេដ្ឋកិច្ចគ្រួសារ

-បន្តអប់រំផ្សព្វផ្សាយ និងជួយដល់ប្រជាកសិករក្នុងការតម្កល់និងរក្សាទឹកសម្រាប់ប្រើប្រាស់ក្នុងជីវភាពរស់នៅប្រចាំថ្ងៃ និងការបង្កបង្កើនផល

-បន្តអប់រំផ្សព្វផ្សាយដល់ប្រជាកសិករដែលធ្វើស្រូវចម្ការឱ្យប្តូរពូជស្រូវដើម្បីបង្កើនទិន្នផលនិងយកចិត្តទុកដាក់ជំរុញការប្រុងប្រយ័ត្នបង្ការភ្លើងឆេះស្រូវជាយថាហេតុក្នុងរដូវប្រាំងនេះ

-ពិនិត្យ និងពង្រឹងឡើងវិញនូវមធ្យោបាយនិងសម្ភារៈផ្សេងៗដើម្បីត្រៀមលក្ខណៈជួយអន្តរាគមន៍មានដូចជា ៖ ស្រូវ

ពូជនិងពូជបន្លែ មធ្យោបាយនានាសម្រាប់អន្តរាគមន៍ដល់គ្រោះរាំងស្ងួត (អន្តរាគមន៍បូមបាច) និងមធ្យោបាយសម្ភារៈនានាដើម្បីទប់ទល់ជំងឺសត្វនិងជំងឺឫសត្វចង្រៃបំផ្លាញដំណាំ។ល។

-ការបន្តរៀបចំពង្រឹងសហគមន៍កសិកម្ម ក៏ដូចជាការរៀបចំគំរូការធ្វើផលិតកម្មកសិកម្មតាមកិច្ចសន្យាឆ្ពោះទៅរកការធ្វើកសិពាណិជ្ជកម្ម

-ចូលរួមធ្វើតេស្តអន្តរមន្ទីរពិសោធន៍លើកទី ១០៥ ជាមួយ IRA (International Rubber Association)

-អង្កេតទូទៅស្ថានភាពជំងឺគ្រប់ឡូត៍ពិសោធន៍ក្លូនកៅស៊ូនិងត្រួតពិនិត្យជំងឺកៅស៊ូ

-ចុះពិនិត្យនៅតាមបណ្តាមន្ទីរពិសោធន៍យថាប្រភេទនិងរោងចក្រកែច្នៃកៅស៊ូ

-រៀបចំគម្រោងបណ្តុះបណ្តាលបច្ចេកទេសចិញ្ចឹមសត្វនៅតាមបណ្តារាជធានី ខេត្ត

-ថែទាំសុខភាព តាមដានជំងឺសត្វ និងមានវិធានការអន្តរាគមន៍តាមការចាំបាច់

-ត្រៀមលក្ខណៈចុះអនុវត្តវិធានបសុពេទ្យនៅកន្លែងផ្ទុះជំងឺនិងកន្លែងដែលមានការឆ្លងរាលដាលជំងឺផ្តាសាយបក្សី និងជំងឺផ្តាសាយ (A) H1N1

-ពង្រឹងទប់ស្កាត់ចរាចរណ៍សត្វនិងផលិតផលសត្វតាមទីស្នាក់ការត្រួតពិនិត្យច្រកទ្វារអន្តរជាតិ ច្រកទ្វារព្រំដែនទ្វេភាគី ច្រកទ្វារតំបន់ព្រំដែន និងច្រកទ្វារកំពង់ផែសមុទ្រ

-ចុះផ្សព្វផ្សាយអំពីលក្ខណៈនិងសញ្ញាណជំងឺជ្រូកត្រចៀកខៀវ ប៉េស្ត និងវិធានការទប់ស្កាត់នៅតាមរាជធានី ខេត្ត

-ចុះតាមដានសកម្មភាពចាក់ថ្នាំការពារជំងឺគោ ក្របី និងពិនិត្យស្ថានភាពជំងឺសត្វនៅតាមរាជធានី ខេត្ត

-ពង្រឹងការអនុវត្តច្បាប់ស្តីពីព្រៃឈើនិងបទបញ្ជារបស់រាជរដ្ឋាភិបាលលេខ០១ និង០២

-បន្តជំរុញកំណត់ព្រំប្រទល់ដែនព្រៃឈើ ធ្វើចំណាត់ថ្នាក់ និងចុះបញ្ជិកាសម្បត្តិព្រៃឈើអចិន្ត្រៃយ៍ឲ្យមានការចូលរួមប្រកបដោយប្រសិទ្ធភាពពីគ្រប់ភាគីពាក់ព័ន្ធ ហើយត្រូវសម្រេចឲ្យបានប្រវែង១.០០០គីឡូម៉ែត្រ

-ជំរុញដាក់ឲ្យដេញថ្លៃជាសាធារណៈចំពោះឈើដែលបានរឹបអូសតាមសាលក្រមរបស់តុលាការនិងតាមការពិន័យអន្តរការណ៍

-បន្តតាមដានត្រួតពិនិត្យនិងវាយតម្លៃប្រសិទ្ធភាពនៃកម្មវិធី ដោយលើកកម្ពស់កម្រិតជីវភាពប្រជាជននៅតាមតំបន់ជនបទ ស្ថិរភាពធនធានព្រៃឈើ និងការពង្រីកសហគមន៍ព្រៃឈើឲ្យបានកាន់តែទូលំទូលាយ ដោយរៀបចំបែបបទទទួលស្គាល់ជាផ្លូវការ និងអភិវឌ្ឍសហគមន៍ព្រៃឈើថ្មីចំនួន១០០កន្លែងបន្ថែមទៀត

-បន្តសហការជាមួយដៃគូនានាអនុវត្តគម្រោងការបណ្តុះបណ្តាល ដើម្បីពង្រឹងសមត្ថភាពរដ្ឋបាលព្រៃឈើនិងភាគីពាក់ព័ន្ធ

-បន្តលើកកម្ពស់គុណភាពនិងប្រសិទ្ធភាពនៃការអប់រំផ្សព្វផ្សាយពីសារប្រយោជន៍ស្តីពីព្រៃឈើ តាមរយៈការផលិតសម្ភារនិងឯកសារបច្ចេកទេស

-បន្តបង្កើនសកម្មភាពសិក្សាស្រាវជ្រាវ និងអភិវឌ្ឍព្រៃឈើសត្វព្រៃតាមរយៈការធ្វើបច្ចុប្បន្នភាពផែនការយុទ្ធសាស្ត្រ និងផែនការសកម្មភាពស្រាវជ្រាវ

-កំណត់តំបន់ព្រៃឈើរេចរឹលឲ្យបានច្បាស់ ដើម្បីធ្វើការស្តារព្រៃឈើឡើងវិញឲ្យក្លាយជាតំបន់ព្រៃឈើមានតម្លៃពាណិជ្ជកម្មដោយធ្វើការដាំដុះប្រភេទឈើប្រណិតមានតម្លៃនិងថែរក្សាការពារចម្ការព្រៃពូជ ព្រមជាមួយការប្រមូលពូជឈើ

-បន្តចូលរួមជាមួយគណៈកម្មការអន្តរក្រសួងចុះដេញថ្លៃផល អនុផលព្រៃឈើដែលរឹបអូសដោយសាលក្រម ដីកាសម្រេច ពិន័យអន្តរការណ៍ និងឈើអញ្ញាតជន(ឈើគ្មានម្ចាស់)នៅទូទាំងប្រទេស

-បន្តបង្កើនកិច្ចសហប្រតិបត្តិការល្អជាមួយស្ថាប័ន សមត្ថកិច្ចជំនាញ និងភាគីពាក់ព័ន្ធនានា ជាពិសេសអ្នកសារព័ត៌មាននិងព្រះរាជអាជ្ញាឲ្យជួយគាំទ្រដល់ការងារពង្រឹងការអនុវត្តច្បាប់ប្រកបដោយតម្លាភាពនិងប្រសិទ្ធភាពខ្ពស់

-រៀបចំសេចក្តីណែនាំនិងដាក់ឲ្យប្រើប្រាស់សៀវភៅកត់ត្រាឈើចេញចូលតាមរោងសន្និធិផល អនុផលព្រៃឈើ

-ពង្រឹងសមត្ថភាពមន្ត្រីរដ្ឋបាលជលផលគ្រប់លំដាប់ថ្នាក់និងអ្នកពាក់ព័ន្ធក្នុងការគ្រប់គ្រងវិស័យជលផល

-បន្តជំរុញការត្រួតពិនិត្យ និងតាមដានការបង្ក្រាបបទល្មើសនេសាទ

-រៀបចំបោះបង្គោលបេតុងចំនួន១៥០បង្គោល និងសាងសង់ស្នាក់ការល្បាតចំនួន១៦កន្លែងនៅកន្លែងអភិរក្សជលផល

-បន្តពង្រឹងសមត្ថភាពសហគមន៍នេសាទ

-រៀបចំនិងអនុវត្តវិធានការការពារដែននេសាទនិងធនធានជលផល

-បន្តស្រាវជ្រាវដកហូតនិងបោះបង្គោលដីព្រៃលិចទឹកដែលកាន់កាប់អនាធិបតេយ្យដោយសហការជាមួយអាជ្ញាធរពាក់ព័ន្ធ

-រៀបចំផ្លូវភ្លើងនិងប៉មយាមសម្រាប់ត្រួតពិនិត្យភ្លើងឆេះព្រៃ

-បន្តបង្កើត និងពង្រឹងសហគមន៍ស្រះជម្រកត្រីបន្ថែមទៀតឲ្យបានគ្រប់ឃុំ

-បន្តរៀបចំទិវាមច្ឆជាតិ១កក្កដារៀងរាល់ឆ្នាំ សំដៅបង្កើនការយល់ដឹង អំពីសារៈសំខាន់ដល់ធនធានជលផល

-ជំរុញការអនុវត្តផែនការសកម្មភាពឆ្នាំ២០១៤ ដើម្បីបង្កើនផលនេសាទទឹកសាប (នេសាទដាយត្រី នេសាទគ្រួសារក្នុងដែននេសាទ នេសាទគ្រួសារក្នុងវាលស្រែ) អាជីវកម្មនេសាទសមុទ្រ វារីវប្បកម្ម (ការចិញ្ចឹមត្រី បង្គា ការចិញ្ចឹមក្រពើ ការផលិតកូនត្រីពូជ) ការកែច្នៃផលនេសាទ (ការកែច្នៃផលនេសាទទឹកសាប ការកែច្នៃផលនេសាទសមុទ្រ ការផលិតទឹកត្រី) ការនាំចេញផលនេសាទនិងការបង្កើនផលចំណូលថវិកាជាតិ

-ពង្រឹងការងារបញ្ជីការគណនេយ្យនៅតាមបណ្តាអង្គភាពក្រោមឱវាទនិងបណ្តាមន្ទីរកសិកម្មរាជធានី-ខេត្ត ក៏ដូចជាការតម្រង់ទិសទៅរកការអនុវត្តថវិកាតាមកម្មវិធីនៅឆ្នាំ២០១៥

-បន្តចុះពិនិត្យផ្ទាល់ដល់ទីវាលរបស់ក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ច ដើម្បីមានមូលដ្ឋានរាយការណ៍ឲ្យបានច្បាស់លាស់និងការប្រមូលចំណូលបង់ចូលថវិកាជាតិ

-បន្តយកចិត្តទុកដាក់លើការសិក្សាស្រាវជ្រាវនិងកសាងគោលការណ៍លិខិតបទដ្ឋានណែនាំជាសារាចរ សេចក្តីណែនាំអំពីការងារគ្រប់គ្រងមន្ត្រីរាជការ និងរៀបចំបែបបទការអនុវត្តជាក់ស្តែងក្នុងការគ្រប់គ្រងធនធានមនុស្សឲ្យល្អប្រសើរតាមប្រព័ន្ធគ្រប់គ្រងព័ត៌មានវិទ្យា ដោយចងក្រងតាមកម្រិតសញ្ញាបត្រ មុខជំនាញ និងតាមមុខតំណែង

-ពង្រឹងការគ្រប់គ្រងនិងអភិវឌ្ឍធនធានមនុស្សឲ្យបានសមស្របទៅតាមច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការនៃព្រះរាជាណាចក្រកម្ពុជា ក៏ដូចជាការអនុវត្តអនុសាសន៍ប្រកបដោយគតិបណ្ឌិតរបស់ តេជោសែន អំពីការដំឡើងកាំប្រាក់មន្ត្រីរាជការឲ្យបានលឿនដើម្បីលើកទឹកចិត្តដល់មន្ត្រីរាជការឲ្យខិតខំប្រឹងប្រែងធ្វើការប្រកបដោយប្រសិទ្ធភាព

-ពង្រឹងពង្រីកកិច្ចសហប្រតិបត្តិការជាតិ-អន្តរជាតិ ក្នុងវិស័យកសិកម្មឲ្យបានទូលំទូលាយជាមួយគ្រប់ដៃគូពាក់ព័ន្ធទាំងអស់

-បន្តរៀបចំលិខិតបទដ្ឋានគតិយុត្តក្រោមច្បាប់ស្តីពីព្រៃឈើ ច្បាប់ស្តីពីជលផល ច្បាប់ស្តីពីការគ្រប់គ្រងពូជដំណាំនិងសិទ្ធិអ្នកបង្កាត់ពូជដំណាំ ច្បាប់ស្តីពីការគ្រប់គ្រងថ្នាំកសិកម្មនិងជីកសិកម្ម ច្បាប់ស្តីពីសហគមន៍កសិកម្ម ដើម្បីធានាដល់ប្រសិទ្ធភាពពេញលេញក្នុងការអនុវត្ត

-បន្តរៀបចំច្បាប់ផ្សេងៗទៀតតាមផ្នែកនីមួយៗតាមការចាំបាច់ ដូចជាច្បាប់ស្តីពីកៅស៊ូ ច្បាប់ស្តីពីការគ្រប់គ្រងដីកសិកម្ម ច្បាប់ស្តីពីសត្វព្រៃនិងជីវចម្រុះ ដើម្បីធានាដល់ដំណើរការប្រព្រឹត្តទៅរបស់អង្គភាពក្រោមឱវាទឲ្យបានសមស្រប។

រាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែ មករា ឆ្នាំ២០១៤

**រដ្ឋមន្ត្រី**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**បណ្ឌិត អ៊ុក រ៉ាប៊ុន**